# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


## វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# “ទស្សនៈរបស់គ្រូ និងនាយកសាលាលើការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិត្រូវទៅនឹងតម្រូវការរបស់ខ្លួន”

The perception of teachers and principals on helping students to choose the appropriate subjects to study in High School according to their needs.

(Case study : Kampong Cham Province)


ដោយ/by

**ឡុង ចំណាន**

LONG CHAMNAN


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**


ឧបត្ថម្ភដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education

## និក្ខេបបទ

## “ទស្សនៈរបស់គ្រូ និងនាយកសាលាលើការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិត្រូវទៅនឹងតម្រូវការរបស់ខ្លួន”

The perception of teachers and principals on helping students to choose the appropriate subjects to study in High School according to their needs.

(Case study : Kampong Cham Province)

**ដោយ**/by

**ឡុង ចំណាន**

LONG CHAMNAN

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**
**ឯកទេស៖ គ្រប់គ្រងអប់រំ**
**ឆ្នាំសិក្សា ២០១៧-២០១៩**

**សាស្ត្រាចារ្យដឹកនាំ៖ បណ្ឌិត ស៊ីន សេងហុក**
**សាស្ត្រាចារ្យដឹកនាំរង៖ ឌី បុណ្ណា**

**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**
Supported by Cambodia International Education Support Foundation ( CIESF )

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៦២៩ **អយក.** ប្រក

**(ការសម្រាត់)**

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈួក ច័ន្ទនាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# **សេចក្តីប្រកាសរបស់បេក្ខជន**

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ទស្សនៈរបស់គ្រូ និងនាយកសាលាលើការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិ ត្រូវទៅនឹងតម្រូវការរបស់ខ្លួន**" សម្រាប់បំពេញលក្ខខណ្ឌ សញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់ ត្រូវបានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេនិង ពុំមានសេចក្តីដកស្រង់ ឬ ខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើពិតជាស្រាវជ្រាវដោយខ្ញុំបាទផ្ទាល់ប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

**ហត្ថលេខាបេក្ខជន**

**ឡុង ចំណាន**

# **លិខិតបញ្ជាក់**

លោកបណ្ឌិត ស៊ិន សេងហុក ជាសាស្ត្រាចារ្យដឹកនាំ

លោក ឌី បុណ្ណា ជាសាស្ត្រាចារ្យដឹកនាំរង

## **សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ឡុង ចំណាន** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ទស្សនៈរបស់គ្រូ និងនាយកសាលាលើការជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិ ត្រូវទៅនឹងតម្រូវការរបស់ខ្លួន**"ពិតប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

.................................... ..................................

**លោកបណ្ឌិត ស៊ិន សេងហុក**
ប្រធាននាយកដ្ឋាននីតិកម្ម

**លោក ឌី បុណ្ណា**
នាយករងវិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមថ្លែងអំណរគុណដល់ ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំ និងផ្តល់អាហារូបករណ៍ ក៏ដូចជាផ្តល់ឱកាសដល់រូបខ្ញុំបាទបានចូលរួមសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងសាស្ត្រាចារ្យដឹកនាំបង្គោល សាស្ត្រាចារ្យដឹកនាំរង លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានខិតខំ ប្រឹងប្រែង ពន្យល់ណែនាំ និងបង្ហាត់បង្រៀនដល់រូបខ្ញុំ និងសិស្សានុសិស្សដទៃទៀតឱ្យទទួលបាននូវចំណេះដឹងពិតប្រាកដ។

សូមអរគុណដល់លោកឪពុក ឡុង ងួនរី និងអ្នកម្តាយ មាឃ គឹមហ៊ាន់ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ ថែរក្សា ផ្តល់ដំបូន្មានដល់រូបខ្ញុំតាំងពីតូច រហូតដល់ពេលនេះ។

សូមអរគុណដល់មិត្តរួមថ្នាក់ ជំនាន់ទី៦ ទាំងអស់ដែលតែងតែផ្តល់ភាពរីករាយ ចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ដែលធ្វើឱ្យរូបខ្ញុំកាន់តែមានទឹកចិត្តតស៊ូ និងខិតខំរៀនសូត្ររហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ។

ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះគណៈគ្រប់គ្រង សាលាគោលដៅ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ដែលបានចូលរួមឆ្លើយសំណួរ និងជួយសម្របសម្រួលក្នុងដំណើរការចុះប្រមូលទិន្នន័យ ឱ្យទទួលបានជោគជ័យ។

សូមប្រសិទ្ធពរជ័យជូនដល់ ឯកឧត្តម សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ លោក លោកស្រីទាំងអស់មានសុខភាពមាំមួន ប្រាជ្ញាវាងវៃដើម្បីបន្តបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេសកម្ពុជាឱ្យក្លាយជាបញ្ញវន្តពិតប្រាកដ។

សូមអរគុណ!

# មូលន័យសង្ខេប

គោលបំណងនៃការស្រាវជ្រាវលើប្រធានបទទស្សនៈរបស់គ្រូបង្រៀន និងនាយកសាលាលើការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិត្រូវទៅនឹងតម្រូវការរបស់ខ្លួន គឺផ្តោតសំខាន់តែទៅលើថ្នាក់បណ្តុំមុខមុខវិជ្ជាសិក្សាវិទ្យាសាស្ត្រសង្គម និងថ្នាក់បណ្តុំមុខវិជ្ជាសិក្សាវិទ្យាសាស្ត្រពិតប៉ុណ្ណោះ។ ដូចគ្នានេះដែរការសិក្សា ធ្វើចំពោះតែគ្រូបង្រៀនកម្រិតទុតិយភូមិ និងនាយកវិទ្យាល័យក្នុងខេត្តកំពង់ចាម ដែលមានអ្នកចូលរួមសរុប៧៦ នាក់។ ការសិក្សាស្រាវជ្រាវបានកំណត់ទស្សនៈយល់ឃើញរបស់គ្រូបង្រៀន និងនាយកសាលាចំនួនបីចំនុចគឺ ទីមួយ) ទស្សនៈចំពោះការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សារបស់សិស្ស ទីពីរ) ទស្សនៈចំពោះការបែងចែកថ្នាក់បណ្តុំមុខវិជ្ជាសិក្សាឱ្យបានល្អ និងទីបី) ទស្សនៈចំពោះវិធីសាស្ត្រនៃការតម្រង់ទិសសិស្សឱ្យជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាបានត្រឹមត្រូវ។ តាមរយៈលទ្ធផលនៃការស្រាវជ្រាវបង្ហាញថា គ្រូបង្រៀន និងនាយកសាលាមានទស្សនៈចំពោះការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សារបស់សិស្សគឺ ផ្អែកលើចំណង់ចំណូលចិត្តរបស់ខ្លួន ហើយចង់ឱ្យមានការបែងចែកថ្នាក់ទៅតាមសមត្ថភាពរបស់សិស្ស ប៉ុន្តែយល់ថាការជួយប្រឹក្សាដល់សិស្សជារួម គឺជាវិធីសាស្ត្រដែលអាចតម្រង់ទិសឱ្យជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាបានត្រឹមត្រូវ។ វាហាក់បីដូចជា គ្រូបង្រៀន និងនាយកសាលាមានទស្សនៈចំពោះវិធីសាស្ត្រនៃការតម្រង់ទិសសិស្ស ដោយផ្តោតសំខាន់លើការផ្តល់ប្រឹក្សា ឬណែនាំជារួម មុនពេលបែងចែកសិស្សទៅតាមថ្នាក់បណ្តុំមុខវិជ្ជាសិក្សាតាមសមត្ថភាពរបស់សិស្ស តែគួរត្រូវប្រើវិធីសាស្ត្រឱ្យសមស្របដើម្បីវាស់ស្ទង់សមត្ថភាពរបស់សិស្សផងដែរ។

# ABSTRACT

The purpose of this research topic “The perception of teachers and school principals on helping students to choose the appropriate subjects to study in High School according to their needs” is only focused on the Social Subject Classes and Scientific Subject Classes. The study was surveyed 76 upper secondary teachers and high school principals in Kampong Cham province. There were three main points about this study: 1) The perception about setting subject classes for students ‘choice. 2) The perception for classifying students into the appropriate classes. 3) The perception for helping students to choose the appropriate setting subject classes. The study found that teachers and school principals thought students have chosen the setting subject classes according to their favorite and wanted to classify students into the ability-group classroom. However, they thought that the best way to help students to choose the appropriate setting subject classes was by providing advice as a group for students. It seems that teachers and school principals want to help students by focusing on the advice for students as a whole before taking their setting subject classes options.

# មាតិកា

សេចក្តីប្រកាសរបស់បេក្ខជន ....... i

លិខិតបញ្ជាក់ ....... ii

សេចក្តីថ្លែងអំណរគុណ ....... iii

មាតិកា ....... vi

សេចក្តីផ្តើម ....... 2

១.១ សាវតា ....... 2

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ....... 6

១.៣ គោលបំណងនៃការស្រាវជ្រាវ ....... 7

១.៤ សំណួរស្រាវជ្រាវ ....... 7

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ....... 8

១.៥.១ សិស្ស ....... 8

១.៥.២ គ្រូបង្រៀន និងនាយកសាលា ....... 8

១.៥.៣ អ្នករៀបចំគោលនយោបាយ ....... 8

១.៦ វិសាលភាពនៃការស្រាវជ្រាវ ....... 9

១.៦.១ ខ្លឹមសារ ....... 9

១.៦.២ ប្រជាជន និងវិភាគសំណាក ....... 9

១.៦.៣ អថេរ ....... 9

១.៦.៤ ពេលវេលា ....... 9

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....... 10

រំលឹកទ្រឹស្តី ....... 13

២.១ ទស្សនៈទូទៅអំពីការបែងចែកថ្នាក់បណ្តុំមុខវិជ្ជា ....... 13

២.២ គោលការណ៍ច្បាប់ និងគោលនយោបាយថ្នាក់បណ្តុំមុខវិជ្ជា ....... 17

២.៣ បច្ចេកទេសអនុវត្ត ....... 20

២.៣.១ ការបែងចែកថ្នាក់បណ្តុំមុខវិជ្ជា ....... 20

២.៣.២ ថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ....... 24

២.៣.៣ ថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រពិត ........ 26
២.៣.៤ ថ្នាក់បណ្តុំមុខវិជ្ជាផ្សេងៗទៀត ........ 27
វិធីសាស្ត្រនៃការស្រាវជ្រាវ ........ 31
៣.១ ព័ត៌មានទូទៅអំពីការស្រាវជ្រាវ ........ 31
៣.២ ការជ្រើសរើសសំណាក ........ 32
៣.៣ ឧបករណ៍នៃការស្រាវជ្រាវ ........ 34
៣.៤ ការប្រមូលទិន្នន័យ ........ 36
៣.៥ ការវិភាគទិន្នន័យ ........ 37
៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ ........ 39
លទ្ធផលនៃការស្រាវជ្រាវ ........ 41
៤.១ ទស្សនៈចំពោះការយល់ឃើញរបស់នាយក និងគ្រូបង្រៀន ........ 41
៤.២ ទស្សនៈនៃការយល់ឃើញរបស់គ្រូបង្រៀន ........ 42
៤.២.១ ការជ្រើសរើសតាមចំណូលចិត្តរបស់សិស្ស ........ 42
៤.២.២ ការជ្រើសរើសតាមឪពុកម្តាយ ........ 43
៤.២.៣ ការជ្រើសរើសតាមលំដាប់ពិន្ទុនៃមុខវិជ្ជា ........ 44
៤.២.៤ តាមមធ្យមភាគនៃការប្រឡង ........ 45
៤.២.៥ តាមការប្រឹក្សាយោបល់ ........ 46
៤.២.៦ តាមតម្រូវការទីផ្សារការងារ ........ 47
៤.៣ ទស្សនៈនៃការយល់ឃើញរបស់នាយកសាលា ........ 48
៤.៣.១ ការជ្រើសរើសតាមចំណូលចិត្តរបស់សិស្ស ........ 48
៤.៣.២ ការជ្រើសរើសតាមឪពុកម្តាយ ........ 48
៤.៣.៣ ការជ្រើសតាមលំដាប់ពិន្ទុនៃមុខវិជ្ជា ........ 50
៤.៣.៤ ការជ្រើសរើសតាមមធ្យមភាគនៃការប្រឡង ........ 51
៤.៣.៥ ការជ្រើសរើសតាមការប្រឹក្សាយោបល់ ........ 52
៤.៣.៦ ការជ្រើសរើសតាមតម្រូវការទីផ្សារការងារ ........ 53
៤.៤ ទស្សនៈទូទៅនៃការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជា ........ 54

៤.៤.១ ទស្សនៈនៃការបែងចែកថ្នាក់រៀន ..... 54
៤.៤.២ ទស្សនៈចំពោះការតម្រង់ទិសសិស្សឱ្យជ្រើសរើសថ្នាក់បណ្ដុំមុខវិជ្ជាសិក្សាបានត្រឹមត្រូវ..... 58
៤.៥ បញ្ហាប្រឈមនៃការជ្រើសរើសថ្នាក់បណ្ដុំមុខវិជ្ជាសិក្សា ..... 59
៤.៥.១ កម្រិតសាលារៀន ..... 59
៤.៥.២ គ្រូបង្រៀន ..... 60
៤.៥.៣ សិស្ស..... 60
សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍..... 62
៥.១ សេចក្ដីសន្និដ្ឋាន ..... 62
៥.២ សំណូមពរ និងអនុសាសន៍..... 63
ឯកសារយោង ..... 66
ឧបសម្ព័ន្ធទី១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ..... 70
ឧបសម្ព័ន្ធទី២៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម..... 73
ឧបសម្ព័ន្ធទី៣៖ កម្រងសំណួរ..... 75

# ជំពូកទី១

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១.១ សាវតា

សង្គមមនុស្សតែងតែវិវឌ្ឍន៍ពីមួយថ្ងៃទៅមួយថ្ងៃឥតឈប់ឈរ ចាប់តាំងពីមុនបុរេប្រវត្តិ រហូតមកដល់ពេលបច្ចុប្បន្ន។ កាលពីដំបូងឡើយមនុស្សរស់នៅតាមធម្មជាតិសុទ្ធសាធ មិនទាន់ចេះបង្កើតវត្ថុប្រើប្រាស់ ឬកែច្នៃធម្មជាតិយកមកប្រើជាប្រយោជន៍ដល់ការរស់នៅរបស់ខ្លួននោះទេ។ ប៉ុន្តែមនុស្សបានរៀនសូត្របន្តិចម្តងៗ ដោយរៀនរស់នៅសម្របទៅតាមធម្មជាតិ និងមានអ្នកខ្លះទៀតបានកែច្នៃធម្មជាតិទៅតាមបំណងរបស់ពួកគេបានយ៉ាងប្រសើររហូតមកដល់ពេលបច្ចុប្បន្ន។ ជាក់ស្តែងចាប់តាំងពីបដិវត្តឧស្សាហកម្មចំហាយទឹក ក្នុងសតវត្សទី១៧ រហូតមកដល់បដិវត្តឧស្សាហកម្មទី៤ គឺឧស្សាហកម្មប្រាជ្ញាសិប្បនិម្មិត្តនាសតវត្សទី២១នេះគឺកើតឡើងដោយសារការសិក្សាស្រាវជ្រាវឥតឈប់ឈររបស់មនុស្ស និងការមានគំនិតច្នៃប្រឌិតរបស់ប្រើប្រាស់ផ្សេងៗទៅតាមតម្រូវការរបស់សង្គមមនុស្ស។ ទាំងអស់នេះគឺកើតចេញពីការសិក្សា រៀនសូត្រ បង្កើតចំណេះដឹងថ្មីៗ ដែលមនុស្សធ្លាប់បានឆ្លងកាត់ពីមុនមក។

វិស័យអប់រំ មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និងសមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព (ក្រសួងអប់រំ ២០១៩)។

ការអប់រំសម្រាប់ទាំងអស់គ្នា និងគោលដៅអភិវឌ្ឍន៍សហសវត្សដែលទាក់ទងនឹងការអប់រំ និងដោះស្រាយបញ្ហាប្រឈមការអប់រំសកល និងថ្នាក់ជាតិ ត្រូវបានបំផុសគំនិតដោយទស្សនវិស័យកតម្រូវការមនុស្សជាធំនៃការអប់រំ និងការអភិវឌ្ឍដោយផ្អែកលើសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរក៏ដូចជាយុត្តិធម៌សង្គម ការរួមបញ្ចូលគ្នា ការការពារ ភាពសម្បូរបែបនៃវប្បធម៌ ភាសា និងភាពចំរុះពូជសាសន៍ និងការទទួលខុសត្រូវរួមគ្នា (សេចក្តីប្រកាសទីក្រុងអ៊ីនឈ័ន ២០១៥)។ នៅក្នុងសេចក្តីប្រកាសទីក្រុងអ៊ីនឈ័ន ក៏បានលើកឡើងដោយកំណត់យកចក្ខុវិស័

យថ្មីសម្រាប់វិស័យអប់រំសម្រាប់ឆ្ពោះទៅរកគោលដៅឆ្នាំ២០៣០ ត្រូវឆ្លើយតបយ៉ាងពេញលេញដោយSDG4 បានស្នើឡើងថា ″ធានាឱ្យបាននូវការអប់រំមានគុណភាព បរិយាបន្ន សមធម៌ រួមទាំងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា″។

កម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំឆ្លើយតបនឹងបរិបទ តំបន់ សកលលោក ដែលមានមហិច្ឆតា និងវិសាលភាពធំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិតក្នុងក្របខណ្ឌទូលំទូលាយគ្របដណ្តប់លើគ្រប់ប្រភេទ និងកម្រិតនៃការអប់រំ ជាពិសេសស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ (ក្រសួងអប់រំ ២០១៩)។

ស្របទៅនឹងនិន្នាការនៃការអប់រំនៅក្នុងតំបន់ និងពិភពលោក ក្រសួងអប់រំ យុវជន និងកីឡានៃប្រទេសកម្ពុជាបានធ្វើកំណែទម្រង់វិស័យអប់រំជាបន្តបន្ទាប់ ដោយនៅក្នុងកំណែទម្រង់វិស័យអប់រំសម្រាប់រយៈពេល៥ឆ្នាំ ២០១៩-២០២៣ បានកំណត់យកនូវគោលនយោបាយចំនួនពីរ គឺទីមួយ "ធានាគុណភាពនៃការអប់រំ ប្រកបដោយសមធម៌ និងបរិយបន្ន និងលើកកម្ពស់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា″ និងគោលនយោបាយទីពីរគឺ "ធានាភាពសក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង សម្រាប់មន្ត្រីគ្រប់គ្រងគ្រប់ជាន់ថ្នាក់″។ ទាំងនេះគឺដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី៣ (២០១៤-២០១៨) និងដំណាក់កាលទី៤ (២០១៩-២០២៣) ដែលផ្តល់អាទិភាពទៅលើមនុស្ស (ក្រសួងអប់រំ ២០១៩)។

ចាប់តាំងពីឆ្នាំ២០១៤មក ក្រសួងអប់រំបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើគុណភាពនៃការអប់រំ ដោយបានធ្វើកំណែទម្រង់ជាច្រើនជាពិសេសទៅលើការប្រឡងមធ្យមសិក្សាទុតិយភូមិ គុណភាពគ្រូបង្រៀន គុណភាពនាយកសាលា និងក្របខណ្ឌកម្មវិធីសិក្សា។ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញសរសរស្តម្ភ៥ គឺទី១ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ទី២ ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា សៀវភៅសិក្សា និងការកែលម្អ

បរិស្ថានសិក្សា ទី៣ ការដាក់អនុវត្តអធិការកិច្ច ទី៤ ការពង្រឹងវង្វាយតម្លៃលទ្ធផលសិក្សា និងទី៥ ការកំណែទម្រង់ឧត្តមសិក្សា (ក្រសួងអប់រំ ២០១៩)។

គុណភាពអប់រំបានទទួលរងឥទ្ធិពលពីកត្តាជាច្រើន ជាពិសេសកម្មវិធីសិក្សាដែលរួមបញ្ចូលទាំងឯកសារពាក់ព័ន្ធនឹងក្របខណ្ឌកម្មវិធីសិក្សាកម្មវិធីសិក្សាលម្អិត សៀវភៅគ្រូ សៀវភៅសិស្ស អនុវត្តសម្ភារៈឧបទេស មន្ទីរពិសោធន៍វិទ្យាសាស្ត្រ និងសៀវណែនាំអំពីការវាយតម្លៃសមត្ថភាពសិស្ស (ក្រសួងអប់រំ ២០១៥)។ ការរៀបចំបែបនេះគឺទាមទារឱ្យមានការស្រាវជ្រាវ និងពិគ្រោះយោបល់ឱ្យបានល្អិតល្អន់ទៅលើមុខវិជ្ជា និងមុខវិជ្ជារងនីមួយៗ ដើម្បីឱ្យទំនាក់ទំនងខ្លឹមសារមេរៀន មានភាពប្រទាក់ក្រឡាគ្នាទៅតាមការបែងចែកនៃការអភិវឌ្ឍកម្មវិធីសិក្សាតាមលក្ខណៈវិទ្យាសាស្ត្រ ដែលកំណត់ច្បាស់លាស់អំពីវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទាដែលសិស្សត្រូវទទួលបានក្រោយរៀនមេរៀននីមួយៗ។

ដោយមើលឃើញពីភាពចាំបាច់នៃការរៀបចំ និងអភិវឌ្ឍកម្មវិធីសិក្សាឱ្យស្របទៅនឹងនិន្នាការពិភពលោកនាពេលបច្ចុប្បន្នចំពោះការរៀន និងបង្រៀន ហើយក៏ជាត្រីវិស័យសម្រាប់សិស្សានុសិស្សអាចចាប់យកនូវចំណេះដឹង ជំនាញ និងជាទុនដ៏សំខាន់សម្រាប់តម្រង់ទិសនៃការសិក្សានៅសាកលវិទ្យាល័យផងដែរនោះ ដូចនេះហើយក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការរៀបចំឱ្យមានថ្នាក់មុខវិជ្ជាវិទ្យាសាស្ត្រសង្គម ថ្នាក់មុខវិជ្ជាវិទ្យាសាស្ត្រ និងថ្នាក់អប់រំបច្ចេកទេសចំណេះទូទៅ សម្រាប់សិស្សានុសិស្សបន្ទាប់ពីបានប្រឡងបញ្ចប់មធ្យមសិក្សាបឋមភូមិដោយជោគជ័យ ទៅតាមបំណង និងតម្រូវការរបស់ខ្លួន។ យ៉ាងណាក៏ដោយតាមការវិភាគពីស្ថានភាពឧត្តមសិក្សានាពេលកន្លងមកបានបង្ហាញពីភាពមិនស៊ីគ្នារវាងការអប់រំ និងទីផ្សារការងារ។ យោងទៅតាមរបាយការណ៍ផ្សេងៗគ្នា មុខជំនាញសិក្សាដែលមានប្រជាប្រិយភាពក្នុងចំណោមនិស្សិតកម្ពុជា គឺវិទ្យាសាស្ត្រសង្គម និងមុខវិជ្ជាទាក់ទងនឹងវិស័យធុរកិច្ច។ និស្សិតមួយចំនួយតូចប៉ុណ្ណោះ សិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងកសិកម្ម ដែលជាមុខជំនាញគន្លឹះ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា (គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា២០៣០, ២០១៤)។

ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងបច្ចេកទេស បានបែងចែកថ្នាក់បណ្ដុំមុខវិជ្ជាសិក្សាវិទ្យាសាស្ត្រសង្គម និងថ្នាក់បណ្ដុំមុខវិជ្ជាសិក្សាវិទ្យាសាស្ត្រពិតសម្រាប់ថ្នាក់ទី១១ និងទី១២ ត្រូវបានចងក្រង និងដាក់ឱ្យអនុវត្តចាប់តាំងពីឆ្នាំសិក្សា២០១១-២០១២មកម្ល៉េះ (ក្រសួងអប់រំ ២០១១)។ ប៉ុន្តែចាប់តាំងពីឆ្នាំ២០១៤ មកក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តនូវកំណែទម្រង់ក្នុងវិស័យអប់រំ ជាពិសេសគឺការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១២ ហើយបើតាមលទ្ធផលបានបង្ហាញឱ្យឃើញថា គុណភាពអប់រំចំណេះទូទៅនៅមានកម្រិតនៅឡើយនាពេលបច្ចុប្បន្ន។ សិស្សមួយចំនួនបោះបង់ការសិក្សាមុនពេលពួកគេចេះអាន និងសរសេរ។ អក្ខរកម្មវិជ្ជាជីវៈរបស់សិស្សនៅមានកម្រិត បើទោះបីពួកគេបានបញ្ចប់បឋមសិក្សា ឬមធ្យមសិក្សាទុតិយភូមិក៏ដោយ។ ចំនួនសិស្សមិនដល់ហាសិបភាគរយទេដែលបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំ ២០១៤ (ក្រសួងអប់រំ ២០១៥)។

ដោយមើលឃើញពីបញ្ហាប្រឈមនានាដែលបានកើតមាន និងដើម្បីជាដំណោះស្រាយសម្រាប់វិស័យអប់រំទាំងមូល ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់ជាច្រើនជាពិសេស គឺគុណភាពគ្រូបង្រៀន គុណភាពនាយកសាលារៀន គុណភាពសម្ភារឧបទ្ទេស និងគុណភាពកម្មវិធីសិក្សា។ ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងបច្ចេកទេស បានរៀបចំ និងចងក្រងឡើងដើម្បីជួយពង្រឹងដល់ការរៀន និងបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាពខ្ពស់ស្របទៅតាមបរិបទសង្គម តំបន់ និងពិភពលោក នោះគឺការរៀបចំឱ្យមានការរៀន និងបង្រៀនថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រពិត នៅកម្រិតមធ្យមសិក្សាទុតិយភូមិសម្រាប់មធ្យមសិក្សាចំណេះទូទៅ ចាប់ពីថ្នាក់ទី១០ ដល់ទី១២ ដោយបានធ្វើការកែសម្រួល និងអភិវឌ្ឍពីក្របខណ្ឌកម្មវិធីសិក្សាចាស់ឱ្យបានល្អប្រសើរឡើង (ក្រសួងអប់រំ ២០១៥)។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ចាប់តាំងពីមានកំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំក្នុងឆ្នាំសិក្សា២០១៤ មកបាន បង្ហាញថា សិស្សានុសិស្សថ្នាក់ទី១២ប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួន តិច។ ហេតុផលមួយក្នុងចំណោមមូលហេតុជាច្រើនគឺថា ពួកគេជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជា សិក្សាមិនបានត្រឹមត្រូវតាមសមត្ថភាពរបស់ពួកគេ ដោយភាគជ្រើសរើសយកថ្នាក់បណ្តុំមុខ វិជ្ជាសិក្សាវិទ្យាសាស្ត្រពិត។ ប៉ុន្តែក្រោយមកដោយមើលឃើញពីស្ថានភាពនៃការប្រឡងចាប់ ផ្តើមរឹតបន្តឹង អ្នកចេះគឺជាប់ បានធ្វើឱ្យសិស្សានុសិស្សចាប់ផ្តើមប្តូរនិន្នាការនៃការជ្រើសរើស ថ្នាក់បណ្តុំមុខវិជ្ជាសិក្សាវិទ្យាសាស្ត្រពិត មករៀនថ្នាក់បណ្តុំមុខវិជ្ជាសិក្សាវិទ្យាសាស្ត្រសង្គម ភាគច្រើនវិញ។ ទាំងនេះបង្ហាញថា ការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សានៅកម្រិតទុតិយភូមិ មិនបានសមស្របទៅនឹងគោលនយោបាយរបស់ក្រសួង និងសមត្ថភាពរបស់សិស្សានុសិស្ស នៅឡើយទេ។

នៅក្នុងការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាសម្រាប់សិស្សានុសិស្សមធ្យមសិក្សាទុតិ ភូមិ ជាទូទៅមិនបានឆ្លងកាត់ការប្រឡងដើម្បីធ្វើការជ្រើសរើសចូលរៀនអាស្រ័យលើសមត្ថ ភាពរបស់ពួកគេទេ។ ពេលខ្លះពួកគេតម្រូវឱ្យរៀនថ្នាក់បណ្តុំមុខវិជ្ជាសិក្សា ដែលសាលារៀនជា អ្នកកំណត់។ ម្យ៉ាងវិញទៀតសិស្សានុសិស្ស ចំនួនភាគច្រើនត្រូវចូលរៀននៅតាមថ្នាក់បណ្តុំ មុខវិជ្ជាសិក្សាវិទ្យាសាស្ត្រពិត ឬវិទ្យាសាស្ត្រសង្គម អាស្រ័យលើពួកគេផ្ទាល់ ឬដោយសារមូល ហេតុនៃការចង់ជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិជាមុនសិន។

តើគ្រូបង្រៀន និងនាយកសាលាយល់យ៉ាងណាចំពោះការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជា សិក្សានៅមធ្យមសិក្សាទុតិយភូមិក្នុងពេលបច្ចុប្បន្ន? តើគ្រូបង្រៀន និងនាយកសាលាមានឥទ្ធិ ពលលើការជួយតម្រង់ទិសសិស្សឱ្យជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាដែរ ឬទេ? តើគ្រូ បង្រៀន និងនាយកសាលាអាចជួយតម្រង់ទិសសិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាឱ្យ ត្រូវទៅតាមសមត្ថភាពរបស់សិស្សដោយរបៀបណា?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះគឺមានគោលបំណងដើម្បីៈ

សិក្សាពីទស្សនៈរបស់គ្រូបង្រៀន និងនាយកសាលាលើការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិ និងការជួយតម្រង់ទិសសិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាត្រូវទៅនឹងតម្រូវការរបស់ខ្លួន។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបតាមគោលបំណងស្រាវជ្រាវខាងលើ ការសិក្សានេះនឹងឆ្លើយសំណួរដូចខាងក្រោមៈ

១. តើគ្រូបង្រៀន និងនាយកសាលាយល់យ៉ាងណាលើការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិនាពេលបច្ចុប្បន្ន?

២. តើគ្រូបង្រៀន និងនាយកសាលាអាចជួយតម្រង់ទិសសិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាឱ្យត្រូវទៅនឹងសមត្ថភាពរបស់ខ្លួនដោយរបៀបណា?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះគឺដើម្បីជាប្រយោជន៍ដល់៖

### ១.៥.១ សិស្ស

- ផ្តល់នូវជម្រើសដ៏ត្រឹមត្រូវសម្រាប់សិស្សានុសិស្សបន្តរៀននៅមធ្យមសិក្សាទុតិយភូមិ
- កាត់បន្ថយការត្រួតថ្នាក់ និងការបោះបង់ការសិក្សា
- ជួយពង្រឹងការសិក្សា និងបង្កើនសមត្ថភាពរបស់សិស្ស
- ជួយតម្រង់ទិសដៅនៃការសិក្សារបស់សិស្ស

### ១.៥.២ គ្រូបង្រៀន និងនាយកសាលា

- ផ្តល់ភាពងាយស្រួលក្នុងដំណើរការបង្រៀន និងរៀន
- បង្កើនប្រសិទ្ធភាពនៃការបង្រៀន
- បង្ហាញការយល់ដឹង និងសេចក្តីត្រូវការរបស់គ្រូបង្រៀន និងនាយកសាលា

### ១.៥.៣ អ្នករៀបចំគោលនយោបាយ

- បង្កើតកម្មវិធីសិក្សាដែលសមស្របសម្រាប់សិស្សានុសិស្ស
- ជួយសិស្សឱ្យមានជំនាញ និងចំណេះដឹងពិតប្រាកដ
- រៀបចំកម្មវិធីសិក្សាលម្អិតបានល្អ និងមានប្រសិទ្ធភាព
- ជួយសិស្សអាចជ្រើសរើសយកជំនាញសិក្សានៅសាកលវិទ្យាល័យបានត្រឹមត្រូវ

## ១.៦ វិសាលភាពនៃការស្រាវជ្រាវ

### ១.៦.១ ខ្លឹមសារ

ការសិក្សាអំពីទស្សនៈរបស់គ្រូ និងនាយកសាលាលើការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិត្រូវតាមតម្រូវការរបស់ខ្លួន គឺផ្អែកទៅលើទ្រឹស្តីដែលមានស្រាប់ធ្លាប់អនុវត្តនៅប្រទេសផ្សេងៗ និងគោលការណ៍ច្បាប់ដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា។

### ១.៦.២ ប្រជាជន និងវិភាគសំណាក

ដោយសារពេលវេលា និងធនធានមានកំណត់ ការសិក្សាស្រាវជ្រាវនេះធ្វើឡើងតែទៅលើ សិស្សានុសិស្ស គ្រូបង្រៀនកម្រិតទុតិយភូមិ និងនាយកសាលារៀន នៅមធ្យមសិក្សាទុតិយភូមិតែប៉ុណ្ណោះ។ ហើយជ្រើសរើសស្រុកចំនួនបី នៅក្នុងខេត្តកំពង់ចាម និងធ្វើការសិក្សាស្រាវជ្រាវនៅវិទ្យាល័យចំនួនប្រាំបួន នាយកវិទ្យាល័យ ចំនួនប្រាំបួននាក់ គ្រូបង្រៀនកម្រិតទុតិយភូមិចំនួនហុកសិបប្រាំពីរនាក់ និងសិស្សចំនួនកៅសិបបួននាក់។

### ១.៦.៣ អថេរ

១. អថេរឯករាជ្យដូចជា៖ (១) ភេទ (ស្រី/ប្រុស) (2) តួនាទី (នាយក/គ្រូបង្រៀន) (៣) អង្គភាព (៤) ឯកទេសដើម (៥) អាយុ (៦) ចំណូលចិត្តរបស់សិស្សនៅក្នុងការរៀន។

២. អថេរមិនឯករាជ្យមានដូចជា៖ (១) មូលហេតុដែលសិស្សានុសិស្សជ្រើសរើសបណ្តុំមុខវិជ្ជារៀន (២) ការបែងចែកថ្នាក់រៀន (ថ្នាក់វិទ្យាសាស្ត្រសង្គម និងថ្នាក់វិទ្យាសាស្ត្រពិត) (៣) ទស្សនៈដើម្បីតម្រង់ទិសសិស្សឱ្យជ្រើសរើសបណ្តុំមុខវិជ្ជាឱ្យបានត្រឹមត្រូវ។

### ១.៦.៤ ពេលវេលា

ការចុះប្រមូលទិន្នន័យដែលបានជ្រើសរើសតាមសាលាគោលដៅមានរយៈពេលមួយខែគឺ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ ២០១៩។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ លើប្រធានបទ "ទស្សនៈរបស់គ្រូ និងនាយកសាលា លើការជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិត្រូវទៅតាមតម្រូវការរបស់ខ្លួន" ករណីសិក្សាក្នុងខេត្តកំពង់ចាមនេះត្រូវបានចែកជា ៥ជំពូកដូចខាងក្រោម៖

### ជំពូកទី១៖ សេចក្តីផ្តើម

នៅក្នុងជំពូកទី១ ជាសេចក្តីផ្តើម យើងបានសិក្សាទៅលើ និន្នាការអប់រំរបស់ពិភពលោក តំបន់ និងប្រទេសកម្ពុជា។ ការសិក្សាបានចាប់ផ្តើមផ្តោតជាដំបូងទៅលើ ចំណុចដៅរបស់ពិភពលោកឆ្នាំ២០៣០ គឺការអភិវឌ្ឍប្រកបដោយចីរភាព និងជាបន្តបន្ទាប់មកទៀតគឺផ្តោតទៅលើការវិវត្តនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះវិស័យអប់រំ និងចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍឥតឈប់ឈរនៅក្នុងវិស័យអប់រំ និងបច្ចេកវិទ្យា នាពេលបច្ចុប្បន្ន និងនាពេលអនាគតផងដែរ។ ម្យ៉ាងវិញទៀតជំពូកនេះបានបង្ហាញពីគោលបំណងនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ លំនាំនៃការស្រាវជ្រាវ និងសារៈសំខាន់នៃការស្រាវជ្រាវ ដើម្បីកំណត់នូវកត្តាសំខាន់ផ្សេងៗ ដែលធ្វើឱ្យគ្រូបង្រៀន និងនាយកសាលាមានទស្សនៈយ៉ាងណាចំពោះការជួយតម្រង់ទិសសិស្សឱ្យជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាបានត្រឹមត្រូវ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

### ជំពូកទី២៖ រំលឹកទ្រឹស្តី

ផ្នែកនេះគឺជាការលើកយកមកសរសេរឡើងវិញនូវទស្សនៈ និងទ្រឹស្តីរបស់អ្នកនិពន្ធទាំងឡាយដែលទាក់ទងនឹងចំណុចក្នុងចំណោទបញ្ហា។

### ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

ជំពូកនេះនឹងបរិយាយអំពីវិធីសាស្ត្រនៃការស្រាវជ្រាវ និងគម្រោងនៃការវិភាគ ដោយកំណត់ទៅលើអថេរឯករាជ្យ អថេរមិនឯករាជ្យ និងអថេរអន្តរាគមន៍ សម្រាប់ការសិក្សា។ ការ

សិក្សានឹងបង្ហាញពីការកំណត់ពេលវេលា និងទីកន្លែងគោលដៅដែលត្រូវសិក្សាស្រាវជ្រាវ។ ការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ ការប្រើប្រាស់ឧបករណ៍ស្ថិតិ ការប្រើរូបមន្តសម្រាប់ការគណនា និងជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ។

## ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា

ផ្នែកនេះលើកឡើងពីលក្ខណៈជាក់ស្តែង ដែលយើងបានធ្វើការស្រាវជ្រាវរួចហើយ ចំណុចដែលត្រូវលើកយកមកនិយាយ និងពិភាក្សា គឺត្រូវឆ្លើយតបទៅនឹងចំណុចដែលបានចោទសួរទាំងអស់ដែលមាននៅក្នុងចំណោទបញ្ហា។ ការពិភាក្សាត្រូវធ្វើយ៉ាងលម្អិតទៅលើវត្ថុបំណងនៃការស្រាវជ្រាវ ដោយយោងទៅលើលទ្ធផលនៃការសិក្សា ទ្រឹស្តី ឬខ្លឹមសារដែលមាននៅក្នុងកម្រងសំណួរ។

## ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ផ្នែកនេះនឹងធ្វើការសង្ខេបការសិក្សាស្រាវជ្រាវ រួចទាញជាការសន្និដ្ឋានលើគ្រប់ចំណុចដែលបានវិភាគ និងផ្តល់ជាយោបល់ ឬសំណូមពរទៅលើចំណុចដែលត្រូវកែលម្អ។

# ជំពូកទី២

# រំលឹកទ្រឹស្តី

## រំលឹកទ្រឹស្តី

## ២.១ ទស្សនៈទូទៅអំពីការបែងចែកថ្នាក់បណ្តុំមុខវិជ្ជា

ការបែងចែកថ្នាក់រៀនគឺមានច្រើនប្រភេទអាស្រ័យទៅលើប្រព័ន្ធអប់រំនៅក្នុងប្រទេសនីមួយៗ និងការចង់បានរបស់សាលារៀន។ ជាទូទៅការបែងចែកថ្នាក់រៀន ចែកជាថ្នាក់បណ្តុំសមត្ថភាពចម្រុះ(Mixed-ability grouping) និងថ្នាក់បណ្តុំតាមសមត្ថភាព(Ability grouping)។

ការកំណត់បែងចែកសិស្សដោយផ្អែកទៅលើសមត្ថភាពនៃការសិក្សា ត្រូវបានទទួលស្គាល់ថា ជារបៀបបែងចែកសិស្សទៅតាមសមត្ថភាពដែលបានអនុវត្តតាំងពីឆ្នាំ១៩៧៦មកនៅក្នុងប្រទេស ណូវ៉ែលសេឡង់ (Phillipa Butler and Dr Kama Weir, 2013)។ យ៉ាងណាក៏ដោយការអនុវត្តការបែងចែកសិស្សទៅតាមសមត្ថភាព បានទទួលការប្រឆាំងយ៉ាងច្រើនកំឡុងទសវត្សឆ្នាំ១៩៧០ ហើយនៅក្នុងការពិនិត្យឡើងវិញរបស់លោក Elley បានផ្តោតយ៉ាងសំខាន់ទៅលើការស្រាវជ្រាវជាលក្ខណៈអន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងសំណួរជាច្រើនពាក់ព័ន្ធនឹងការអប់រំនៅពេលនោះ។ លោក Elley បានសន្និដ្ឋានថា "សរុបសេចក្តីមក ការបែងចែកសិស្សទៅតាមសមត្ថភាព តាមការស្រាវជ្រាវជាលក្ខណៈអន្តរជាតិបានជំទាស់ថា ការបែងចែកសិស្សតាមសមត្ថភាពជាទូទៅមិនបានកើនឡើងនៃភាពជោគជ័យរបស់សិស្សទេ (Gamoran, 1992; Ireson, Hallam &Hurtley, 2005; Salvin, 1990)។ តាមពិតទៅ ការបែងចែកសិស្សទៅតាមសមត្ថភាពអាចកើនឡើងនូវវិសមភាពរវាងសិស្សានុសិស្សថែមទៀតផង (Gamoran, 1992; Hanushek & Woessmann, 2005)។ សិស្សដែលមានសមត្ថភាពខ្ពស់ទំនងជារៀនទទួលបានលទ្ធផលល្អនៅក្នុងប្រព័ន្ធបែងចែកនេះ ផ្ទុយមកវិញសិស្សានុសិស្សដែលមកពីគ្រួសារមានជីវភាពទាប សិស្សានុសិស្សជនជាតិភាគតិច និងសិស្សានុសិស្សមកពីគ្រួសារអន្តោប្រវេសន៍ទទួលបានលទ្ធផលមិនល្អដែលត្រូវរៀននៅក្នុងថ្នាក់មានសមត្ថភាពទាប (Scholfield, 2010)។ នៅក្នុងបរិបទប្រទេស ណូវ៉ែលសេឡង់ លោក Hornby, លោក Witte និងលោក Mitchell (2011) បានលើកឡើងថា ភាពជោគជ័យនៃការសិក្សារបស់សិស្ស ទទួលបានពីប្រព័ន្ធការបែងចែកថ្នាក់តាមសមត្ថភាព គឺនៅមានកម្រិតតិចតួចប៉ុណ្ណោះ។ ហើយជាការពិតណាស់ មានការ

ទទួលស្គាល់ជាច្រើនពីគុណវិបត្តិនៃការបែងចែកថ្នាក់តាមសមត្ថភាព ទៅលើការកើនឡើងនៃបញ្ហាអាកប្បកិរិយារបស់សិស្ស ការថយចុះការលើកទឹកចិត្ត និងបន្ទាបការគោរពចំពោះខ្លួនឯងរបស់សិស្សដែលមិនស្ថិតនៅក្នុងថ្នាក់ដែលមានសមត្ថភាពខ្ពស់”។

ការសិក្សាផ្សេងទៀតបានលើកឡើងថា ភាពជោគជ័យនៃការសិក្សានៅក្នុងប្រទេសអង់គ្លេសគឺ មានឥទ្ធិពលយ៉ាងខ្លាំងពីការរៀបចំថ្នាក់រៀនដែលសិស្សានុសិស្សមកពីគ្រួសារមានឋានៈ និងជីវភាពខ្ពស់ងាយទទួលបានជោគជ័យ ជាងសិស្សានុសិស្សមកពីគ្រួសារមានឋានៈទាប និងជីវភាពមិនល្អ(Cliffton & cook, 2012)។ គម្លាតរវាងសិស្សានុសិស្សអាចឱ្យយើងបានដឹងនៅពេលដែលពួកគេមានអាយុ៣ឆ្នាំ(Feinstein, 2003) ហើយបន្តរហូតដល់ពួកគេមានអាយុកាន់តែច្រើន(Feinstein, 2004)។ មានវិធីមួយក្នុងចំណោមវិធីសាស្ត្រជាច្រើនសម្រាប់ធ្វើការវាស់វែងសមត្ថភាពដើម្បីកាត់បន្ថយវិសមភាពគឺ ការរៀបចំថ្នាក់រៀនទៅតាមសមត្ថភាពសិស្ស។ វិធីនេះគឺរៀបចំឱ្យសិស្សានុសិស្សរៀននៅក្នុងថ្នាក់រៀនជាមួយគ្នាដោយផ្អែកលើពិន្ទុដែលពួកគេទទួលបានពីមុខវិជ្ជាជាក់លាក់ណាមួយ ដូចនេះពួកគេនឹងត្រូវបង្រៀនជាមួយសិស្សដែលមានសមត្ថភាពប្រហាក់ប្រហែលគ្នា(Francis et al, 2017)។ ទិន្នន័យទូទៅនៃការរៀបចំថ្នាក់រៀនទៅតាមសមត្ថភាពគឺមានភាពមិនត្រឹមត្រូវទាំងអស់ទេ ព្រោះមានភស្តុតាងបង្ហាញថាវាត្រូវបានអនុវត្តន៍ជាទូទៅនៅថ្នាក់មធ្យមសិក្សា និងថ្នាក់បឋមសិក្សាមិនមានការអនុវត្តច្រើននោះទេ នៅក្នុងចក្រភពអង់គ្លេស(Dracup, 2014)។ ការរៀបចំថ្នាក់រៀនទៅតាមសមត្ថភាពគឺមានភាពពេញនិយមជាខ្លាំង ជាពិសេសពីឪពុកម្តាយដែលមានជីវភាពមធ្យម(Boaler, Wiliam, Brown; 2000) ដូចនេះហើយមានសាលារៀនជាច្រើនត្រូវបានលើកទឹកចិត្តឱ្យមានការរៀបចំថ្នាក់រៀនទៅតាមទំរង់បែបនេះ។ គុណសម្បត្តិនៃការរៀបចំថ្នាក់រៀនទៅតាមសមត្ថភាពរួមមាន៖ ផ្តល់ភាពងាយស្រួលដល់គ្រូបង្រៀនក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀនដែលឆ្លើយតបទៅតាមសមត្ថភាពផ្សេងៗគ្នារបស់សិស្សនុសិស្សនៅក្នុងថ្នាក់រៀននីមួយៗ ផ្តល់ឱកាសដល់សិស្សានុសិស្សកាន់តែច្រើនដើម្បីបង្កើនសមត្ថភាពរបស់ពួកគេផ្ទាល់ រៀបចំបង្កើតឱ្យមានថ្នាក់រៀនដែលមានចំនួនសិស្សានុសិស្សតិចសម្រាប់ក្រុមសិស្សមានសមត្ថភាពទាប (Ireson,

1999) និងក្រុមសិស្សានុសិស្សដែលស្ថិតនៅក្នុងថ្នាក់រៀនដែលមានសមត្ថភាពទាបទទួលបានការគាំទ្រកាន់តែច្រើន(Francis et al, 2017)។ ទោះបីជាយ៉ាងនេះក៏ដោយ ភាពពេញនិយមរបស់វាមិនមានន័យថាវាផ្តល់ប្រយោជន៍ដល់សិស្សានុសិស្សទាំងអស់ ឬគួរតែត្រូវប្រើប្រាស់វិធីនេះជាទូទៅនោះទេ។ មានកត្តារួមផ្សំជាច្រើនដែលផ្តល់ផលប៉ះពាល់ជាអវិជ្ជមានដល់លទ្ធផលរបស់សិស្សានុសិស្ស នៅពេលដែលពួកគេត្រូវបានរៀបចំឱ្យរៀននៅក្នុងថ្នាក់ដោយផ្អែកលើពិន្ទុបានពីការប្រឡង។ បញ្ហាមួយក្នុងចំណោមបញ្ហាចំបងជាច្រើននោះគឺ ពិន្ទុបានពីការប្រឡងរបស់សិស្សានុសិស្ស មិនមែនជាភាពខុសគ្នាតែមួយគត់ដែលអាចកំណត់ថាពួកគេគួរតែឱ្យចូលរៀននៅក្នុងថ្នាក់បណ្តុំមុខវិជ្ជាមួយណានោះទេ។ ការធ្វើហេតុវិនិច្ឆ័យចំពោះថ្នាក់រៀន និងតម្រូវការផ្នែកអប់រំពិសេសក៏ជាការវាយតម្លៃដ៏សំខាន់ផងដែរ(Muijs & Dunne, 2010)។ ការបែងចែកក្រុមសិស្សានុសិស្សទាំងនេះ មិនអាចពន្យល់វែកញែកឱ្យបានពិស្តារសម្រាប់ភាពផ្សេងៗគ្នានៃលទ្ធផលរបស់សិស្ស ឬការផ្តល់ការគាំទ្រមិនបានត្រឹមត្រូវនោះទេ ក្នុងខណៈពេលដែលគុណភាពនៃការអប់រំនៅមានភាពខ្វះខាតរវាងក្រុមសិស្សានុសិស្សទាំងនោះ (Dunne, Hunphreys, Sebba, Dyson, Gallanmaugh, & Muijs; 2007)។ ឧទាហរណ៍ ក្រុមសិស្សានុសិស្សដែលរៀននៅក្នុងថ្នាក់មានសមត្ថភាពទាបគឺ ត្រូវបង្រៀនដោយគ្រូមានសមត្ថភាពអន់(Slavin, 1990) ឬការផ្តល់ការគាំទ្រផ្សេងៗទៀតមិនបានគ្រប់គ្រាន់ផងដែរ។ ការរៀបចំសិស្សទៅតាមសមត្ថភាព អាចបង្កើតឱ្យមានរបាសិប្បនិមិត្តមួយ ដែលសិស្សានុសិស្សត្រូវបានដកចេញពីថ្នាក់ដែលមានសមត្ថភាព និងចំណាត់ថ្នាក់ខ្ពស់។ ចំណែកឯសិស្សានុសិស្សដែលរៀននៅក្នុងថ្នាក់ដែលមានសមត្ថភាពទាប ជារឿយៗតែងតែបង្ហាញការមិនពេញចិត្តនឹងថ្នាក់រៀនរបស់ពួកគេ និងជូនកាលមិនពេញចិត្តសាលារៀនទាំងមូលផងដែរ(Ball, 1981)។

កាសិក្សាបានបង្ហាញថា ការរៀបចំឱ្យសិស្សរៀនទៅតាមការកំណត់របស់សាលារៀនគឺមានភាពល្អប្រសើ ដូចមានការលើកឡើងថា ការកំណត់ឱ្យសិស្សរៀន ជាពិសេសលើមុខវិជ្ជាគណិតវិទ្យា និងភាសា គឺបានបង្ហាញអំពីប្រសិទ្ធភាពនៃការអប់រំនៅក្នុងសាលាជាច្រើន។ ការសិក្សាបានលើកឡើងដោយភាពជឿជាក់ថា គ្មានគម្រូដ៏ល្អឥតខ្ចោះសម្រាប់ការកំណត់បែង

ចែកសិស្សនៅសាលាមធ្យមសិក្សាទេ ប៉ុន្តែប្រសិនបើសាលារៀនមិនអាចរកវិធីសាស្ត្រផ្សេងៗ ដែលមានប្រសិទ្ធ ឱ្យទទួលបានលទ្ធផលល្អប្រសើរទេ យើងអាចសន្និដ្ឋានបានថាការកំណត់បែងចែកសិស្សជាបរិបទដែលសាលារៀនគួរតែអនុវត្តនៅក្នុងសាលារៀន(HMSO, 1997)។ ម្យ៉ាងវិញទៀតនៅក្នុងសៀវភៅស របស់អតីតរដ្ឋាភិបាលអង់គ្លេសក្នុងឆ្នាំ២០០៥ មានចំណងជើងថា "ស្តង់ដារកាន់តែខ្ពស់ សាលារៀនកាន់តែប្រសើរសម្រាប់ទាំងអស់គ្នា" បានសរសេរថា ការកំណត់បែងចែកសិស្សអាចជួយលើកទឹកចិត្ត ជំនាញទំនាក់ទំនងក្នុងសង្គម និងមានភាពឯករាជ្យ ហើយកាន់តែពិសេសនោះគឺ ជួយបង្កើនស្តង់ដារនៃការសិក្សាពីព្រោះសិស្សានុសិស្សមានរបៀបរៀនផ្ទាល់ខ្លួនរបស់ពួកគេ។ ពួកយើងបានជំរុញឱ្យសាលារៀនប្រើប្រាស់វិធីកំណត់បែងចែកសិស្សតាំងពីឆ្នាំ ១៩៩៧ មកម្លេះ (HMSO, 2005, p. 58, our emphasis) ។

## ២.២ គោលការណ៍ច្បាប់ និងគោលនយោបាយថ្នាក់បណ្ដុះមុខវិជ្ជា

### ២.២.១ គោលការណ៍ច្បាប់

នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់ជំពូកទី៦ ស្ដីអំពី អប់រំ វប្បធម៌ និងសង្គមកិច្ច ពីមាត្រាទី៦៥ ដល់មាត្រាទី៦៨ (រដ្ឋធម្មនុញ្ញ ២០០៨)បានចែងថា៖

រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាព នៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។

រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត។

រដ្ឋអនុវត្តកម្មវិធីសិក្សា និង គោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និង ភាសាបរទេស។

រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈ និងឯកជននៅគ្រប់ភូមិសិក្សា។

រដ្ឋផ្ដល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសំរាប់ប្រជាពលរដ្ឋគ្រប់រូប ដោយឥតបង់ថ្លៃ។

ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិច ប្រាំបួនឆ្នាំ។

រដ្ឋជួយផ្សព្វផ្សាយ និង លើកតម្កើងសាលាបាលី និងពុទ្ធិកសិក្សា។

បន្ថែមជាងនេះទៅទៀត រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦បានបន្តអនុវត្ត យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពដោយខិតខំកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ឱ្យក្លាយជាប្រទេសកម្រិតអភិវឌ្ឍ និងប្រជាជនមានប្រាក់ចំណូលកម្រិតខ្ពស់ ដូចនេះហើយរាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្ររបស់ខ្លួន ដោយនៅតែផ្តោតការយកចិត្តទុកដាក់លើវិស័យអាទិភាពចំនួន៤ គឺ មនុស្ស ផ្លូវ ទឹក និងភ្លើង។ ដោយតម្កល់ "មនុស្ស" ជាអាទិភាពនៅលើគេ ដូចនៅក្នុងយុទ្ធសាស្ត្រចតុកោណទី១ បានសរសេរថា៖ ការអភិវឌ្ឍធនធានមនុស្សរួមមាន ១). ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ២). បណ្តុះបណ្តាលជំនាញបច្ចេកទេស ៣). ការលើកកម្ពស់សេវាសុខភាពសាធារណៈ និង អាហារូបត្ថម្ភ និង ៤). ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម (យុទ្ធសាស្ត្រចតុកោណ ២០១៨)។

នៅក្នុងច្បាប់ស្តីពីការអប់រំ ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយឥតកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ និងត្រូវបានព្រះមហាក្សត្រឡាយព្រះហត្ថលេខាលើព្រះរាជក្រម និងបានប្រកាសឱ្យប្រើប្រាស់ច្បាប់អប់រំនេះ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧ (ព្រះរាជក្រម ២០០៧)។ ច្បាប់នេះមានគោលដៅកំណត់វិធាន និងលក្ខខណ្ឌតម្រូវថ្នាក់ជាតិ សម្រាប់កសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពដែលធានាបានគោលការណ៍សេរីភាពខាងសិក្សាធិការ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ហើយច្បាប់នេះក៏មានគោលបំណងអភិវឌ្ឍធនធានមនុស្ស ដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដើម្បីឱ្យអ្នកសិក្សាទទួលបានចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយប្រកបដោយសីលធម៌ សំដៅជំរុញឱ្យអ្នកសិក្សាស្គាល់ស្រលាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ។

ក្នុងមាត្រាទី៨នៃច្បាប់អប់រំ បានចែងថាប្រព័ន្ធអប់រំជាតិមាន៣ភូមិសិក្សារួមមាន បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។ ហើយប្រភេទនៃការសិក្សាចែកជា២គឺ ប្រភេទសិក្សាចំណេះទូទៅ និងប្រភេទសិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈ (ច្បាប់អប់រំ ២០០៧)។

ប្រភេទនៃការសិក្សាទី១គឺ ការអប់រំចំណេះទូទៅ ជាការចាំបាច់ដែលធ្វើឱ្យអ្នកសិក្សាមានការរីកចម្រើនចំណេះដឹង សីលធម៌ បុគ្គលិកលក្ខណៈល្អ ដោយលើកកម្ពស់សមត្ថភាពខាងផ្លូវចិត្ត បញ្ញា កាយ និងចេតនាឱ្យចេះប្រើចំណេះដឹង និងបំណិនមូលដ្ឋាន។ ការអប់រំទូទៅរួមមាន៖(១) ការអប់រំបឋមសិក្សា ឬភូមិសិក្សាទី១ ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ នៃកម្មវិធីអប់រំក្នុងប្រព័ន្ធ (២) ការអប់រំមធ្យមសិក្សា ឬ ភូមិសិក្សាទី២ ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២។ ការអប់រំមធ្យមសិក្សាមានពីរដំណាក់កាល ដំណាក់កាលទី១ មធ្យមសិក្សាបឋមភូមិ ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ និង ដំណាក់កាលទី២ មធ្យមសិក្សាទុតិយភូមិ ចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២ (ច្បាប់ស្តីពីការអប់រំ ២០០៧)។

នៅក្នុងមាត្រាទី១៩នៃច្បាប់អប់រំ គឺបានអធិប្បាយអំពីប្រភេទសិក្សាទី២ ដែលបានសរសេរថា ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គ្របដណ្តប់គ្រប់ជំនាញ មុខរបរ និងបំណិន ដែលត្រូវផ្តល់ឱ្យដោយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ឯកជន សហគ្រាស សហគមន៍ គ្រួសារ ឬដោយសហការរវាងគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងសហគ្រាស និង/ឬសហគមន៍ គ្រួសារ (ច្បាប់ស្តីពីការអប់រំ ២០០៧)។

## ២.៣ បច្ចេកទេសអនុវត្ត

### ២.៣.១ ការបែងចែកថ្នាក់បណ្តុំមុខវិជ្ជា

ចាប់តាំពីឆ្នាំ១៩៧៩ ដល់បច្ចុប្បន្ននេះ ការអភិវឌ្ឍកម្មវិធីសិក្សា មានការផ្លាស់ប្តូរជាបួនដំណាក់កាល (ក្រសួងអប់រំ ២០១៥)។

នៅដំណាក់កាលទី១ ពីឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៧ នាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា កម្មវិធីសិក្សាមានបីកម្រិត៖ កម្មវិធីបឋមសិក្សាវិជ្ជាទូទៅ (កម្រិតសិក្សាទី១) កម្មវិធីកម្រិតសិក្សាទី២ និងកម្មវិធីសិក្សាកម្រិតទី៣។

នៅដំណាក់កាលទី២ ពីឆ្នាំ១៩៨៧ដល់ឆ្នាំ១៩៩៦ នាសម័យរដ្ឋកម្ពុជា កម្មវិធីសិក្សាត្រូវបានបែងចែកជាកម្មវិធីបឋមសិក្សាចំណេះទូទៅ (កម្រិតសិក្សាទី១) កម្មវិធីកម្រិតសិក្សាទី២ និងកម្មវិធីសិក្សាកម្រិតទី៣។

នៅដំណាក់កាលទី៣ ពីឆ្នាំ១៩៩៦ដល់ឆ្នាំ២០០៥ នាសម័យព្រះរាជាណាចក្រកម្ពុជា កម្មវិធីសិក្សារួមមាន កម្មវិធីសិក្សាគោលសម្រាប់បឋមសិក្សា កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាបឋមភូមិ និងកម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយភូមិ។

នៅដំណាក់កាលទី៤ ពីឆ្នាំ២០០៥ដល់ឆ្នាំ២០០៩ នាសម័យព្រះរាជាណាចក្រកម្ពុជាទី២ ក្រសួងអប់រំ យុវជន និងកីឡាបានអភិវឌ្ឍគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ (ពីថ្នាក់ទី១ដល់ទី៩) និងកម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិភូមិ (ពីថ្នាក់ទី១០ដល់ទី១២)។

ទោះបីយ៉ាងណាក៏ដោយ ការអនុវត្តកម្មវិធីសិក្សាដែលបានរួមបញ្ចូលនូវការបែងចែកថ្នាក់បណ្តុំមុខវិជ្ជាសិក្សា គឺបណ្តុំមុខវិជ្ជាសិក្សាវិទ្យាសាស្ត្រ និងបណ្តុំមុខវិជ្ជាសិក្សាវិទ្យាសាស្ត្រសង្គម ត្រូវដាក់ឱ្យប្រើប្រាស់នៅសាលាចំណេះទូទៅចាប់ផ្តើមពីដំណាក់កាលទី៤ និងដំណាក់កាលទី៥ប៉ុណ្ណោះ។

នៅក្នុងកម្មវិធីសិក្សា "ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នាឆ្នាំ" ២០០៣-២០១៥ មិនត្រឹមតែបានចងក្រងនូវឯកសារ កម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិ ដើម្បីពង្រឹង និងពង្រីកចំណេះដឹងដែលសិស្សទទួលបានពីកម្មវិធីសិក្សាអប់រំមូលដ្ឋានប៉ុណ្ណោះទេ គឺថែមទាំងផ្តល់ការសិក្សាបែបតម្រង់ទិស ដើម្បីផ្តល់ឱ្យសិស្សមានសមត្ថភាពអាចបន្តការសិក្សានៅឧត្តមសិក្សា ឬចូលរួមក្នុងជីវភាពសង្គមដោយធានាថាសិស្សនឹងទទួលបាន (ក្រសួងអប់រំ ២០០៤)៖

- ការចេះដឹងកាន់តែខ្ពស់ផ្នែកអក្សរសាស្ត្រខ្មែរ និងគណិតវិទ្យា
- ការស្គាល់អត្តសញ្ញាណជាតិកាន់តែច្បាស់
- ការអភិវឌ្ឍការយល់ដឹងកាន់តែខ្លាំងពី សីលធម៌រស់នៅ និងការទទួលខុសត្រូវរបស់ពលរដ្ឋចំពោះប្រទេសជាតិ
- បំណិនជីវិតប្រចាំថ្ងៃ ចាំបាច់សម្រាប់ការចូលរួមក្នុងជីវភាពសហគមន៍មូលដ្ឋាន និងក្នុងសង្គមកម្ពុជា
- ការយល់ដឹងកាន់តែទូលំទូលាយពីពិភពលោក និងគោលការណ៍វិទ្យាសាស្ត្រ
- សមត្ថភាពកាន់តែខ្ពស់ក្នុងទំនាក់ទំនងជាភាសាបរទេស

ការសិក្សាដោយប្រើប្រាស់ជម្រើសបណ្តុំមុខវិជ្ជាសិក្សានេះគឺអនុវត្តចាប់ពីថ្នាក់ទី១១ និងទី១២ប៉ុណ្ណោះ ហើយសិស្សដែលជ្រើសរើសមុខវិជ្ជាសិក្សានៅថ្នាក់ទី១១ នឹងត្រូវបន្តសិក្សាមុខវិជ្ជាដដែលនៅថ្នាក់ទី១២។

មុខវិជ្ជាជំរើសដែលសាលាផ្តល់ឱ្យអាស្រ័យទៅលើជំរើសរបស់សិស្ស អត្ថិភាពធនធាន និងអត្ថិភាពគ្រូបង្រៀន។ សិស្សទាំងអស់ត្រូវតែរៀនមុខវិជ្ជាចាំបាច់(ដែលខានមិនបាន) ចំនួន៤មុខវិជ្ជាគឺ៖

- អក្សរសាស្ត្រខ្មែរ
- គណិតវិទ្យា (គណិតវិទ្យាកម្រិតមូលដ្ឋាន ឬ គណិតវិទ្យាកម្រិតខ្ពស់)
- ភាសាបរទេស (បារាំង ឬ អង់គ្លេស)
- អប់រំកាយ កីឡា និងសុខភាព

សិស្សដែលជ្រើសរើសមុខវិជ្ជាគណិតវិទ្យាកម្រិតមូលដ្ឋាន ត្រូវជ្រើសរើសមុខវិជ្ជា ៤ ទៀត ពីមុខវិជ្ជាជំរើសមកសិក្សា។ ចំណែកសិស្សដែលជ្រើសរើសមុខវិជ្ជាគណិតវិទ្យាកម្រិតខ្ពស់ ត្រូវរើសមុខវិជ្ជា ៣ ទៀតពីមុខវិជ្ជាជម្រើសមកសិក្សា។ សិស្សអាចមិនជ្រើសរើស ឬ រើសយក១ ឬរើសយក២ ឬរើសយក៣ ពីបណ្តុំមុខវិជ្ជា វិទ្យាសាស្ត្រសង្គម និងកម្មវិធីអប់រំវិជ្ជាជីវៈជំរើស។ ចំនួនអតិបរិមានៃមុខវិជ្ជាដែលសិស្សត្រូវជ្រើសរើសមកសិក្សាគឺ ៨មុខវិជ្ជាចំពោះសិស្ស ដែលសិក្សាគណិតវិទ្យាកម្រិតមូលដ្ឋាន និង ៧មុខវិជ្ជាចំពោះសិស្សដែលសិក្សាគណិតវិទ្យាកម្រិតខ្ពស់ ហើយសិស្សដែលបញ្ចប់ការសិក្សាដោយជោគជ័យនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នឹងទទួលបានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដោយឆ្លងកាត់ការប្រឡងថ្នាក់ជាតិ។

របាយម៉ោងសិក្សាតាមមុខវិជ្ជាសម្រាប់ថ្នាក់ទី១១ និងទី១២៖

| | |
|---|---|
| **មុខវិជ្ជា ចាំបាច់** | **ចំនួនម៉ោងសិក្សាតាមមុខវិជ្ជានីមួយៗ ក្នុង១សប្តាហ៍** |
| **អក្សរសាស្ត្រខ្មែរ** | **៦ម៉ោង** |
| **អប់រំកាយ កីឡា និងសុខភាព** | **២ម៉ោង** |
| **ភាសាបរទេស**<br>ត្រូវជ្រើសរើសយក១ | ភាសាអង់គ្លេស ៤ម៉ោង<br>ភាសាបារាំង ៤ម៉ោង |
| **គណិតវិទ្យា**<br>ត្រូវជ្រើសរើសយក១ | កម្រិតមូលដ្ឋាន ៤ម៉ោង<br>កម្រិតខ្ពស់ ៨ម៉ោង |
| **មុខវិជ្ជាជម្រើស** | **មុខវិជ្ជានីមួយៗ ត្រូវសិក្សា ៤ម៉ោងសិក្សាក្នុង១សប្តាហ៍** |
| **វិទ្យាសាស្ត្រ**<br>អាចមិនជ្រើសរើស ឬរើសយក១ ឬ២ ឬ៣ | រូបវិទ្យា<br>គីមីវិទ្យា<br>ជីវវិទ្យា<br>ផែនដី និង បរិស្ថានវិទ្យា |
| **វិទ្យាសាស្ត្រសង្គម**<br>អាចមិនជ្រើសរើស ឬរើសយក១ ឬ២ ឬ៣ | សីលធម៌/ពលរដ្ឋវិទ្យា<br>ប្រវត្តិវិទ្យា<br>ភូមិវិទ្យា |

<table>
<tr><td></td><td>សេដ្ឋកិច្ច</td></tr>
<tr><td rowspan="5">កម្មវិធីអប់រំវិជ្ជាជីវៈ ជម្រើស<br>អាចមិនជ្រើសរើស ឬរើសយក១ ឬ២ ឬ៣</td><td>បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន(ICT)/បច្ចេកវិទ្យា</td></tr>
<tr><td>គណនេយ្យ/ គ្រប់គ្រងពាណិជ្ជកម្ម</td></tr>
<tr><td>មុខវិជ្ជាបច្ចេកវិទ្យាវិជ្ជាជីវៈតាមមូលដ្ឋាន</td></tr>
<tr><td>ទេសចរណ៍</td></tr>
<tr><td>អប់រំសិល្បៈ ។ល។</td></tr>
<tr><td colspan="2">សិស្សដែលជ្រើសរើសគណិតវិទ្យាកម្រិតមូលដ្ឋាន ត្រូវរើសមុខវិជ្ជា ៤ មកសិក្សា ៖<br>សរុប ១៦ម៉+ (៤x៤)=៣២ម៉ ក្នុង១សប្តាហ៍<br>សិស្សដែលជ្រើសរើសគណិតវិទ្យាកម្រិតខ្ពស់ ត្រូវរើសមុខវិជ្ជា ៣ មកសិក្សា ៖<br>សរុប ២០ម៉+ (៤x៣)=៣២ម៉ ក្នុង១សប្តាហ៍</td></tr>
</table>

ទោះបីជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍកម្មវិធីសិក្សានៅដំណាក់កាលទី៥នេះ គឺពឹងផ្អែកទៅលើគោលនយោបាយការអភិវឌ្ឍកម្មវិធីសិក្សាដំណាក់កាលទី៤ ដើម្បីធ្វើឱ្យសមត្ថភាពសិស្សដែលបញ្ចប់ការសិក្សាពីភូមិសិក្សានីមួយៗមានចំណេះដឹង បំណិន និងឥរិយាបថសម្រាប់ប្រកបកិច្ចការរស់នៅប្រចាំថ្ងៃ និងសម្រាប់បន្តការសិក្សា។ ជាងនេះទៅទៀតក្របខ័ណ្ឌកម្មវិធីសិក្សានេះ គឺធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពអប់រំដែលឆ្លើយតបទៅនឹងការប្រែប្រួលរបស់ពិភពលោក និងឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៤ ដែលបានបង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការប្រែក្លាយទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ សមាហរណកម្មអាស៊ាន និងការប្រែប្រួលរបស់ពិភពលោក ការអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅថ្មីដំណាក់កាលទី៥នេះ ឱ្យកាន់តែមានលក្ខណៈទាន់សម័យ និងវិទ្យាសាស្ត្រសម្រាប់បង្កើតពលរដ្ឋពេញលេញ គឺជាកត្តាអាទិភាព និងចាំបាច់បំផុត (ក្រសួងអប់រំ ២០១៥)។

ចំណុចសំខាន់ៗដែលត្រូវបានកែសម្រួល និងបន្ថែមពីលើគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ២០០៥ដល់ឆ្នាំ២០០៩ ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ដែលត្រូវបានលើកឡើង

នៅក្នុងការសិក្សាស្រាវជ្រាវនានាស្តីអំពីលទ្ធផលសិក្សារបស់សិស្ស ភាពប្រទាក់ក្រឡាគ្នានៃកម្មវិធីសិក្សាពីភូមិសិក្សាមួយ ទៅភូមិសិក្សាមួយទៀត ពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត និងភាពឆ្លើយតបនៃកម្មវិធីសិក្សាពីមធ្យមសិក្សាទៅឧត្តមសិក្សា និងទីផ្សារការងារ។ នោះគឺការរៀបចំទម្រង់នៃប្រព័ន្ធអប់រំថ្មីតាមរចនាសម្ព័ន្ធដែលសិស្សនៅមធ្យមសិក្សាទុតិយភូមិចាប់ពីថ្នាក់ទី១០ទៅ មានជម្រើសបីសម្រាប់ជ្រើសរើស រួមមានវិទ្យាសាស្ត្រពិត វិទ្យាសាស្ត្រសង្គម អប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយអនុលោមទៅតាមក្របខ័ណ្ឌគុណវុឌ្ឍជាតិ (ក្រសួងអប់រំ ២០១៥)។

### ២.៣.២ ថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម

ការសិក្សានៅក្នុងថ្នាក់វិទ្យាសាស្ត្រសង្គម គឺជាថ្នាក់បណ្តុំមុខវិជ្ជាសង្គមសាស្ត្រ និងមនុស្សសាស្ត្រ។ មុខវិជ្ជាសិក្សាសង្គមមានគោលបំណងពង្រឹង និងពង្រីកសមត្ថភាពរបស់សិស្សជាពលរដ្ឋ ដោយការសិក្សាអំពីទ្រឹស្តី និងការអនុវត្តពាក់ព័ន្ធនឹងអត្តសញ្ញាណវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ បរិស្ថាន ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ច្បាប់ និងនយោបាយ។

មុខវិជ្ជាសិក្សាសង្គម មានសមាសភាគដូចខាងក្រោមៈ

- ប្រវត្តិវិទ្យា
- ភូមិវិទ្យា
- សីលធម៌ពលរដ្ឋ
- គេហសេដ្ឋកិច្ចវិទ្យា
- អប់រំសិល្បៈ

គោលបំណងនៃការសិក្សាមុខវិជ្ជាសិក្សាសង្គមគឺជានាឱ្យសិស្សៈ

- ទទួលបានចំណេះដឹង និងបំណិនទាក់ទងទៅនឹងអត្តសញ្ញាណវប្បធម៌ ប្រពៃណី ច្បាប់ ទំនៀមទម្លាប់ បរិស្ថាន ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងនយោបាយរបស់កម្ពុជា និងបណ្តាប្រទេសក្នុងតំបន់

- អភិវឌ្ឍបំណិនពលរដ្ឋពាក់ព័ន្ធទៅនឹងតួនាទី និងការទទួលខុសត្រូវក្នុងនាមជាសិស្ស និងជាពលរដ្ឋទាំងនៅក្នុងសាលារៀន គ្រួសារ សហគមន៍ សង្គមជាតិ និងអន្តរជាតិ
- ប្រើប្រាស់ចំណេះដឹង និងបំណិនដែលបានមកពីការសិក្សាមុខវិជ្ជានានានៅក្នុងមុខវិជ្ជាសិក្សាសង្គមសម្រាប់ការរៀនសូត្រ និងការរស់នៅប្រចាំថ្ងៃ
- ស្រឡាញ់ជាតិ សាសនា និងព្រះមហាក្សត្រក្នុងនាមជាពលរដ្ឋមានការចេះដឹង និងការទទួលខុសត្រូវ មានមោទនភាពចំពោះជាតិរបស់ខ្លួន និងគោរពជាតិសាសន៍ដទៃ។

របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ បណ្តុំវិទ្យាសាស្ត្រសង្គម

| **ល.រ** | **មុខវិជ្ជា** | **ថ្នាក់** | | |
|---|---|---|---|---|
| | | **១០** | **១១** | **១២** |
| ១ | អក្សរសាស្ត្រខ្មែរ | ៦ | ៦ | ៦ |
| ២ | គណិតវិទ្យា | ៥ | ៥ | ៥ |
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |
| ៦ | រូបវិទ្យា | ២ | ២ | ២ |
| ៧ | ផែនដីវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ២ | ២ | ២ |
| ៩ | ជីវវិទ្យា | ២ | ២ | ២ |
| ១០ | ប្រវត្តិវិទ្យា | ៤ | ៤ | ៤ |
| ១១ | ភូមិវិទ្យា | ៣ | ៣ | ៣ |
| ១២ | សីលធម៌ពលរដ្ឋវិទ្យា | ៣ | ៣ | ៣ |
| ១៣ | បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | **៤០** | **៤០** | **៤០** |

សំគាល់៖ _ ៦ថ្ងៃក្នុងមួយសប្តាហ៍ ពី៤ទី៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៥០នាទី។

_ ជីវភាសាទី១ មាន៤ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

### ២.៣.៣ ថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រពិត

ការសិក្សាក្នុងថ្នាក់បណ្តុំវិទ្យាសាស្ត្រ គឺជាការសិក្សាបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រធម្មជាតិ។ មុខវិជ្ជាវិទ្យាសាស្ត្រមានគោលបំណងសំខាន់ចំបងសម្រាប់ស្វែងយល់ពីបាតុភូតធម្មជាតិដោយប្រើប្រាស់វិធីវិទ្យាសាស្ត្រ ដើម្បីធ្វើឱ្យចំណេះដឹងកាន់តែមានសុក្រឹតភាពសម្រាប់ប្រើប្រាស់ក្នុងការសិក្សា ការរស់នៅប្រចាំថ្ងៃ និងធានាបានការអភិវឌ្ឍប្រកបដោយចីរភាព។

មុខវិជ្ជាវិទ្យាសាស្ត្រមានសមាសភាគដូចខាងក្រោម៖

- រូបវិទ្យា
- ផែនដីវិទ្យា
- គីមីវិទ្យា
- ជីវវិទ្យា

គោលបំណងនៃការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រគឺធានាឱ្យសិស្ស៖

- ទទួលបានចំណេះដឹង និងបំណិនវិទ្យាសាស្ត្រមូលដ្ឋានរឹងមាំ ដើម្បីបម្រើវិស័យបច្ចេកទេស និងវិស័យផ្សេងទៀតឱ្យស្របតាមតម្រូវការទីផ្សារការងារ
- មានសមត្ថភាពគិតសមហេតុផល គណនា វិភាគ ពន្យល់ បកស្រាយបានយ៉ាងរហ័ស និងត្រឹមត្រូវតាមវិទ្យាសាស្ត្រ
- អនុវត្តចំណេះដឹង និងបំណិនវិទ្យាសាស្ត្រក្នុងការសិក្សា និងការរស់នៅប្រចាំថ្ងៃ
- ស្គាល់ និងលើកកម្ពស់តម្លៃមុខវិជ្ជាវិទ្យាសាស្ត្រ និងការអនុវត្តវិទ្យាសាស្ត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

របាយមុខវិជ្ជា និងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ ថ្នាក់បណ្តុំវិទ្យាសាស្ត្រ

| **ល.រ** | **មុខវិជ្ជា** | **ថ្នាក់** | | |
|---|---|---|---|---|
| | | **១០** | **១១** | **១២** |
| ១ | អក្សរសាស្ត្រខ្មែរ | ៥ | ៥ | ៥ |
| ២ | គណិតវិទ្យា | ៦ | ៦ | ៦ |
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |
| ៦ | រូបវិទ្យា | ៤ | ៤ | ៤ |
| ៧ | ផែនដីបរិស្ថានវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ៣ | ៣ | ៣ |
| ៩ | ជីវវិទ្យា | ៣ | ៣ | ៣ |
| ១០ | ប្រវត្តិវិទ្យា | ២ | ២ | ២ |
| ១១ | ភូមិវិទ្យា | ២ | ២ | ២ |
| ១២ | សីលធម៌ពលរដ្ឋវិទ្យា | ២ | ២ | ២ |
| ១៣ | បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | **៤០** | **៤០** | **៤០** |

សំគាល់៖_៦ថ្ងៃក្នុងមួយសប្តាហ៍ ពី៤ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៥០នាទី។

_ជីវភាសាទី១ មានរយៈពេល៤ម៉ោងសិក្សានិង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

## ២.៣.៤ ថ្នាក់បណ្តុំមុខវិជ្ជាផ្សេងៗទៀត

ក្រៅពីថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រពិត ក៏នៅមានរបៀបនៃការបែងចែកថ្នាក់ផ្សេងៗដទៃទៀតជាច្រើនដែរ។ ការបែងចែកថ្នាក់ទាំងនោះមានដូចជា ការបែងចែកថ្នាក់រៀនទៅតាមមុខវិជ្ជា(Setting) ការបែងចែកថ្នាក់រៀនទៅតាមសមត្ថ

ភាព(Ability grouping) ការបែងចែកថ្នាក់រៀនតាមសមត្ថភាពចម្រុះ(Mixed-ability grouping) និងការបែងចែកថ្នាក់រៀនបច្ចេកទេស(Vocational Classes)។

#### ២.៣.៤.១ ថ្នាក់អប់រំបច្ចេកទេស

ការអប់រំបច្ចេកទេសត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាបន្ទាប់ពីសិស្សានុសិស្សបញ្ចប់មធ្យមសិក្សាបឋមភូមិប្រកបដោយជោគជ័យ ហើយពួកគេអាចមានជម្រើសក្នុងការបន្តការសិក្សានៅក្នុងសាលារៀនចំណេះទូទៅ ឬក៏សាលារៀនចំណេះទូទៅបច្ចេកទេសរបស់រដ្ឋដែលមានទីតាំងច្រើនកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា (ក្រសួងអប់រំ ២០១៥)។ សម្រាប់មុខវិជ្ជាដែលត្រូវសិក្សាមានពីរ គឺមុខវិជ្ជាចំណេះទូទៅ និងមុខវិជ្ជាវិជ្ជាជីវៈ។ មុខវិជ្ជាចំណេះទូទៅរួមមាន អក្សរសាស្ត្រខ្មែរ ភាសាអង់គ្លេស គណិតវិទ្យា កុំព្យូទ័រ សីលធម៌ពលរដ្ឋវិទ្យា កីឡា វិទ្យាសាស្ត្រ(រូបវិទ្យា ផែនដីបរិស្ថានវិទ្យា គីមីវិទ្យា ជីវវិទ្យា) វិទ្យាសាស្ត្រសង្គម (ប្រវត្តិវិទ្យា ភូមិវិទ្យា គេហសេដ្ឋកិច្ចវិទ្យា)។ មុខវិជ្ជាវិជ្ជាជីវៈរួមមានមុខវិជ្ជាបច្ចេកទេសវិជ្ជាជីវៈ និងមុខវិជ្ជាវិជ្ជាជីវៈតាមតំបន់។ ហើយការអប់រំបច្ចេកទេសនេះរួមបញ្ចូលទាំងសកម្មភាពជម្រើស និងកម្មសិក្សា (ក្រសួងអប់រំ ២០១៥)។

របាយមុខវិជ្ជា និងម៉ោងសិក្សាឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣

<table>
<tr><th colspan="3">មុខវិជ្ជា</th><th>ឆ្នាំទី១</th><th>ឆ្នាំទី២</th><th>ឆ្នាំទី៣</th></tr>
<tr><td rowspan="8">មុខវិជ្ជា ចំណេះទូទៅ</td><td colspan="2">អក្សរសាស្ត្រខ្មែរ</td><td>១១៤ម៉ោង</td><td>១១៤ម៉ោង</td><td>១១៤ម៉ោង</td></tr>
<tr><td colspan="2">ភាសាអង់គ្លេស</td><td>៧៦ម៉ោង</td><td>៧៦ម៉ោង</td><td>៧៦ម៉ោង</td></tr>
<tr><td colspan="2">គណិតវិទ្យា</td><td>១១៤ម៉ោង</td><td>១១៤ម៉ោង</td><td>១១៤ម៉ោង</td></tr>
<tr><td colspan="2">កុំព្យូទ័រ</td><td>៧៦ម៉ោង</td><td>៧៦ម៉ោង</td><td>៧៦ម៉ោង</td></tr>
<tr><td colspan="2">សីលធម៌ពលរដ្ឋវិទ្យា</td><td>៣៨ម៉ោង</td><td>៣៨ម៉ោង</td><td>០ម៉ោង</td></tr>
<tr><td colspan="2">កីឡា</td><td>៣២ម៉ោង</td><td>៣២ម៉ោង</td><td>៣២ម៉ោង</td></tr>
<tr><td rowspan="2">វិទ្យាសាស្ត្រ ឬ</td><td>រូបវិទ្យា(១)</td><td>៧៦ម៉ោង</td><td>៧៦ម៉ោង</td><td>៧៦ម៉ោង</td></tr>
<tr><td>គីមីវិទ្យា(២))</td><td>៧៦ម៉ោង</td><td>៧៦ម៉ោង</td><td>៧៦ម៉ោង</td></tr>
</table>

| | | | | | |
|---|---|---|---|---|---|
| | វិទ្យាសាស្ត្រសង្គម | សេដ្ឋកិច្ច[៣] | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | | ប្រវត្តិ ភូមិវិទ្យា | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | សរុប | | ៥២៦ម៉ោង | ៥២៦ម៉ោង | ៤៨០ម៉ោង |
| មុខវិជ្ជាវិជ្ជាជីវៈ | មុខវិជ្ជាបច្ចេកទេសវិជ្ជាជីវៈ | | ៧៤៩-៧៦៩ ម៉ោង | ៧៤៩-៧៦៩ ម៉ោង | ៧៤៩-៧៦៩ ម៉ោង |
| | មុខវិជ្ជាវិជ្ជាជីវៈតាមតំបន់ | | ៨០-១០០ម៉ោង | ៨០-១០០ម៉ោង | ៨០-១០០ម៉ោង |
| | សរុប | | ៨៤៨ម៉ោង | ៨៤៨ម៉ោង | ៨៤៨ម៉ោង |
| សកម្មភាពជម្រើស | | | ៦ម៉ោង | ៦ម៉ោង | ៦ម៉ោង |
| កម្មសិក្សា | | | | | ៣២០ម៉ោង (មិនរាបបញ្ចូល) |
| **សរុបរួម** | | | **១៣៨០ ម៉ោង** | **១៣៨០ ម៉ោង** | **១៣៣៤ ម៉ោង** |

សំគាល់៖ សិក្សា៦ថ្ងៃក្នុងមួយសប្តាហ៍ បី៤ទៅ៦ម៉ោងសិក្សាក្នុងមួយថ្ងៃ ១ម៉ោងសិក្សាមានរយៈពេល៥០នាទី ១ឆ្នាំសិក្សាមានរយៈពេល៣៨សប្តាហ៍។

[១] *ត្រូវរៀនមុខវិជ្ជារូបវិទ្យា ចំនួន២ម៉ោងសិក្សាក្នុង១សប្តាហ៍ លើមុខជំនាញមេកានិចអេឡិចត្រូនិចឬអគ្គីសនី ដែលមាន៧៦ម៉ោងក្នុងមួយឆ្នាំ*

[២] *ត្រូវរៀនមុខវិជ្ជាគីមីវិទ្យា/ជីវវិទ្យា ចំនួន២ម៉ោងសិក្សាក្នុង១សប្តាហ៍ លើមុខជំនាញក្សេត្រសាស្ត្រឬបសុវប្បកម្ម ដែលមាន៧៦ម៉ោងក្នុងមួយឆ្នាំ*

[៣] *ត្រូវរៀនមុខវិជ្ជាសេដ្ឋកិច្ច ចំនួន២ម៉ោងក្នុង១សប្តាហ៍ លើមុខជំនាញគណនេយ្យនិងគ្រប់គ្រង ដែលមាន៧៦ម៉ោងក្នុងមួយឆ្នាំ។*

# ជំពូកទី៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

## វិធីសាស្ត្រនៃការស្រាវជ្រាវ

### ៣.១ ព័ត៌មានទូទៅអំពីការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងអនុវត្តក្នុងទម្រង់ជាករណីសិក្សា នៅតាមវិទ្យាល័យនានាក្នុងខេត្តកំពង់ចាម។ ដើម្បីឆ្លើយតបនឹងសំណួរស្រាវជ្រាវក្នុងជំពូកទី១ ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំឡើង ដោយប្រើប្រាស់ទិន្នន័យបានមកពីកម្រងសំណួរបែបបរិមាណវិស័យ ដែលមានកម្រងសំណួរជាទម្រង់បិទ និងកម្រងសំណួរបែបជាទម្រង់បើក ដើម្បីសម្រេចនូវវត្ថុបំណងសំខាន់សម្រាប់ការស្រាវជ្រាវនេះ គឺសិក្សាពីទស្សនៈរបស់គ្រូបង្រៀន និងនាយកសាលា លើការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សារបស់សិស្សត្រូវទៅតាមតម្រូវការរបស់ខ្លួន។

ដោយផ្អែកទៅលើកត្តា ភេទ កម្រិតវប្បធម៌នៃការអប់រំ និងបទពិសោធបង្រៀនរបស់គាត់។ ដើម្បីសម្រេចបាននូវវត្ថុបំណងខាងលើនេះ វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណត្រូវបានប្រើប្រាស់ដោយបូកផ្សំជាមួយនឹងព័ត៌មានពីការអង្កេតផ្ទាល់របស់អ្នកស្រាវជ្រាវ ទៅលើស្ថានភាពជាក់ស្តែងរបស់វិទ្យាល័យនីមួយៗដែលបានជ្រើសរើសទាំងនោះ។ ជំពូកទី៣នេះនឹងរៀបរាប់លម្អិតពីវិធីសាស្ត្រក្នុងការស្រាវជ្រាវ ហើយខ្លឹមសារសំខាន់ៗត្រូវបានរៀបចំតាមគោលគំនិតដូចខាងក្រោម៖

១) ព័ត៌មានទូទៅអំពីការស្រាវជ្រាវ

២) ការជ្រើសរើសសំណាក

៣) ឧបករណ៍ស្រាវជ្រាវ

៤) វិធីសាស្ត្រប្រមូលទិន្នន័យ

៥) ការវិភាគទិន្នន័យ

### ៣.២ ការជ្រើសរើសសំណាក

ការស្រាវជ្រាវនេះជ្រើសរើសយកតែខេត្តកំពង់ចាមដើម្បីសិក្សា និងប្រមូលទិន្នន័យ ដូចនេះលទ្ធផលនៃការស្រាវជ្រាវនេះ ពុំអាចធ្វើការឆ្លុះបញ្ចាំងពីទស្សនៈរបស់លោកគ្រូ អ្នកគ្រូ និងនាយកសាលារៀនកម្រិតទុតិយភូមិនៅក្នុងប្រទេសកម្ពុជាទាំងមូលនោះទេ។ ដោយសារតែប្រធានបទនេះពាក់ព័ន្ធទៅនឹងតែទស្សនៈរបស់គ្រូបង្រៀនកម្រិតទុតិយភូមិ និងនាយកសាលារៀននៅកម្រិតវិទ្យាល័យ អ្នកស្រាវជ្រាវបានរៀបចំចងក្រងជាកម្រងសំណួរសម្រាប់ប្រមូលទិន្នន័យ ដោយផ្អែកលើគោលគំនិតបានមកពីគ្រូដឹកនាំនៃការស្រាវជ្រាវ និងឯកសារពាក់ព័ន្ធនានារបស់អ្នកស្រាវជ្រាវពីមុនមក។ កម្រងសំណួរនេះបានបែងចែកដោយផ្តោតទៅលើចំណុចសំខាន់ៗចំនួន៣ និងមាន១៩ សំណួរ។

ចំណុចសំខាន់ៗ ដែលបានចងក្រងនៅក្នុងកម្រងសំណួរនេះមានដូចជា៖

(១) មូលហេតុដែលសិស្សានុសិស្សជ្រើសរើសបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រសង្គម

(២) ការបែងចែកបណ្តុំថ្នាក់រៀនវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម

(៣) ទស្សនៈរបស់គ្រូបង្រៀន និងនាយកសាលារៀនដើម្បីតម្រង់ទិសសិស្សថ្នាក់បណ្តុំមុខវិជ្ជាឱ្យបានត្រឹមត្រូវ

ការស្រាវជ្រាវនេះបានជ្រើសរើសយកវិទ្យាល័យមួយចំនួននៅក្នុងខេត្តកំពង់ចាមដើម្បីធ្វើការសិក្សាស្រាវជ្រាវ ទៅលើទស្សនៈរបស់គ្រូបង្រៀន និងនាយកសាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ នៅក្នុងខេត្តកំពង់ចាមមានស្រុកទាំងអស់ចំនួន១០ និងវិទ្យាល័យចំនួន៤៩ក្នុងចំណោមស្រុកទាំងអស់នេះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកស្រុកចំនួន៣ ដែលជាស្រុកធំ ស្រុកតូច និងស្រុកដាច់ស្រយ៉ាល ហើយបានជ្រើសរើសវិទ្យាល័យចំនួន៩ រួមមាន វិទ្យាល័យស្រេងគីម វិទ្យាល័យល្វា វិទ្យាល័យហ៊ុនសែនព្រៃទទឹង វិទ្យាល័យហ៊ុនសែនគរ វិទ្យាល័យនរោត្តមរណឫទ្ធិគន្ធបុប្ផា វិទ្យាល័យហ៊ុនសែនស្គន់ វិទ្យាល័យហោណាំហុងព្រៃញា វិទ្យាល័យអគ្គមហាសេនាបតីហ៊ុនសែនបាធាយ និងវិទ្យាល័យហ៊ុនសែនសំពងជ័យ។ វិទ្យា

ល័យទាំងនោះមានភាពខុសគ្នាមួយចំនួនដូចជា ស្ថានភាពការសិក្សារបស់សិស្ស ស្ថានភាពការរស់នៅរបស់ប្រជាជននៅជុំវិញសាលារៀន ការរីកចម្រើនរបស់សាលារៀន ព្រមទាំងទីតាំងរបស់សាលារៀន ដែលចំណុចទាំងអស់នេះ នឹងត្រូវប្រើជាព័ត៌មានបន្ថែមក្នុងការពន្យល់បកស្រាយលើលទ្ធផលនៃការស្រាវជ្រាវ។ ចំពោះមូលហេតុដែលជ្រើសរើសយកសាលារៀនចំនួន៩ ក្នុងខេត្តកំពង់ចាម មកធ្វើជាសំណាកពីព្រោះអាស្រ័យ លើពេលវេលា និងធនធានសម្រាប់ជាធ្វើដំណើរ និងការចំណាយផ្សេងៗមានកំណត់ ទើបអ្នកស្រាវជ្រាវសម្រេចយកតែសាលារៀនចំនួនប៉ុណ្ណឹង។ សម្រាប់សំណាកដែលត្រូវជ្រើសរើសសរុបមាននាយកសាលារៀនចំនួន ៩នាក់ គ្រូបង្រៀនចំនួន ៦៧នាក់ និងសិស្សានុសិស្សកំពុងរៀនកម្រិតមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ ចំនួន២២នាក់ ថ្នាក់ទី១១ ចំនួន២២នាក់ និងថ្នាក់ទី១២ ចំនួន៥០នាក់។

### ៣.៣ ឧបករណ៍នៃការស្រាវជ្រាវ

ដូចដែលបានបញ្ជាក់ក្នុងចំណុច ៣.២ ខាងលើ ការរៀបចំឧបករណ៍ស្រាវជ្រាវផ្តោតសំខាន់ទៅលើ ចំណុចចំនួនបី និងត្រូវបានរៀបចំជាពីរផ្នែកគឺ៖

(ក) ព័ត៌មានពីស្ថានភាពទូទៅរបស់គ្រូបង្រៀន និងនាយកសាលារៀន

ផ្នែកនេះមានសរសេរបញ្ចូលព័ត៌មានដូចជា ឈ្មោះវិទ្យាល័យ ភេទ ឯកទេសដើម និងអាយុជាដើម ដោយចំណុចទាំងនេះ លោកគ្រូ អ្នកគ្រូ និងនាយកសាលារៀនតម្រូវឱ្យជ្រើសរើសនូវជម្រើសមួយដែលបញ្ជាក់ពីស្ថានភាពជាក់ស្តែងរបស់គាត់។

(ខ) ព័ត៌មានទាក់ទងនឹងការតម្រង់ទិសសិស្សជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សា

១. មូលហេតុដែលសិស្សានុសិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត៖

ចំណុចនេះមានចំនួន០៧សំណួរ ដែលប្រើសម្រាប់ធ្វើការវាស់ស្ទង់ការយល់ឃើញនិងស្ថានភាពជាក់ស្តែងរបស់លោកគ្រូ អ្នកគ្រូ និងនាយកសាលារៀនចំពោះការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សារបស់សិស្សានុសិស្សតាមរយៈលើ ចំណាប់ចំណូលចិត្ត ការណែនាំពីគ្រួសារ ការរៀបចំរបស់សាលារៀន តាមតម្រូវការទីផ្សារការងារ តាមកម្រិតពិន្ទុនៃមុខវិជ្ជា និងតាមរយៈការប្រឹក្សាយោបល់ពីអ្នកជំនាញជាដើម។

២. ការបែងចែកថ្នាក់បណ្តុំមុខវិជ្ជាសិក្សា

នៅក្នុងចំណុចនេះមានសំណួរ ចំនួន០៥ ដែលផ្តោតសំខាន់ទៅលើការយល់ដឹង និងសេចក្តីត្រូវការចំពោះការរៀបចំថ្នាក់បណ្តុំមុខវិជ្ជា ដែលផ្តោតលើកម្រិតថ្នាក់ដែលគួរបែងចែកថ្នាក់បណ្តុំមុខវិជ្ជាសិក្សា និងវិធីសាស្ត្រក្នុងការបែងចែកថ្នាក់បណ្តុំមុខវិជ្ជាសិក្សា ដូចជាការបែងចែកថ្នាក់បណ្តុំមុខវិជ្ជាតាមការស្ម័គ្រចិត្តរបស់សិស្ស តាមរយៈពិន្ទុនៃការប្រឡងលើមុខវិជ្ជាមួយចំនួន និងតាមរយៈសមត្ថភាពរបស់សិស្ស។

៣. ទស្សនៈរបស់លោកគ្រូ អ្នកគ្រូ និងនាយកសាលារៀនលើការតម្រង់ទិសសិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាឱ្យបានត្រឹមត្រូវៈ

នៅក្នុងសំណួរជ្រើសរើសនេះ គឺផ្តោតសំខាន់ទៅលើការយល់ឃើញរបស់គ្រូបង្រៀន និងនាយកសាលារៀនអំពីវិធីសាស្ត្រ សម្រាប់ការជួយសិស្សឱ្យជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាបានត្រឹមត្រូវ ដូចជាតាមរយៈ ការណែនាំនៅក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន ការផ្តល់ការប្រឹក្សាយោបល់ដល់សិស្ស និងអាណាព្យាបាល និងការប្រឡងជ្រើសរើសសិស្សឱ្យចូលរៀនជាដើម។ បន្ថែមជាងនេះទៅទៀត ក៏មានសំណួរសម្រាប់ឱ្យបកស្រាយចំនួន២ ដើម្បីឱ្យគ្រូបង្រៀន និងនាយកសាលារៀនឆ្លើយតាមរយៈចំណេះដឹង បទពិសោធន៍ និងការយល់ឃើញរបស់ពួកគាត់អំពីថ្នាក់បណ្តុំមុខវិជ្ជាសិក្សាសព្វថ្ងៃ និងការយល់ឃើញចំពោះការជួយសិស្សឱ្យជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាបានត្រឹមត្រូវ។

## ៣.៤ ការប្រមូលទិន្នន័យ

បន្ទាប់ពីកម្រងសំណួរបានទទួលការពិភាក្សា និងយល់ព្រមពីគ្រូដឹកនាំរង និងគ្រូដឹកនាំបង្គោលដើម្បីធ្វើការសម្ភាសន៍ អ្នកស្រាវជ្រាវក៏បានសរសេរលិខិតស្នើសុំលោកនាយកវិទ្យាស្ថានជាតិអប់រំដើម្បីប្រមូលទិន្នន័យនៅតាមសាលារៀននានាដូចដែលបានកំណត់។

បន្ទាប់មកទៀត អ្នកស្រាវជ្រាវត្រូវយកលិខិតដែលបានទទួលការយល់ព្រមពីវិទ្យាស្ថានជាតិអប់រំ សម្រាប់បង្ហាញដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីសុំសហការណ៍ និងសាកសួរព័ត៌មានបន្ថែមអំពីទីតាំងដែលបានកំណត់ទុកសម្រាប់ការសិក្សាស្រាវជ្រាវនេះ។ បន្ទាប់ពីបានកំណត់វិទ្យាល័យគោលដៅសម្រាប់ការសិក្សាស្រាវជ្រាវរួចហើយ ត្រូវបង្ហាញលិខិតអនុញ្ញាតដល់ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ដើម្បីទទួលការសហការណ៍គ្នាបន្ថែមទៀតមុនពេលចុះទៅសាលារៀនដែលត្រូវចុះប្រមូលទិន្នន័យ។ នៅវិទ្យាល័យនីមួយៗអ្នកស្រាវជ្រាវត្រូវសុំការសហការណ៍ទាំងគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ដើម្បីសម្រួលដល់ការប្រមូលទិន្នន័យទាំងនេះ។

បន្ទាប់ពីបានជួបជាមួយគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សដើម្បីចូលរួមបំពេញកម្រងសំណួររួចមក អ្នកស្រាវជ្រាវបានជួយពន្យល់ណែនាំពីរបៀបបំពេញ និងឆ្លើយនឹងសំណួរនានាដែលពាក់ព័ន្ធទៅនឹងកម្រងសំណួរ ដោយប្រើរយៈពេល៣០នាទី ក្នុងការបំពេញកម្រងសំណួរនីមួយៗ។ ក្រោយពីបំពេញចម្លើយនៅក្នុងកម្រងសំណួររួចរាល់ហើយ អ្នកស្រាវជ្រាវបានប្រមូលសន្លឹកកម្រងសំណួរ និងត្រួតពិនិត្យដើម្បីធ្វើឱ្យប្រាកដថាសំណួរទាំងអស់បានឆ្លើយ និងបំពេញបានចប់សព្វគ្រប់។

ការប្រមូលទិន្នន័យនេះនឹងអាចឱ្យអ្នកស្រាវជ្រាវ ប្រមូលបានព័ត៌មានដ៏មានប្រយោជន៍សម្រាប់ការសិក្សាឈ្វេងយល់បន្ថែមពីទស្សនៈរបស់គ្រូបង្រៀន និងនាយកសាលារៀននៅកម្រិតទុតិយភូមិ ចំពោះការជួយតម្រង់ទិសសិស្សឱ្យជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាបានសមស្របតាមតម្រូវការរបស់ខ្លួន។

## ៣.៥ ការវិភាគទិន្នន័យ

ផ្នែកនេះនឹងបង្ហាញព័ត៌មានទូទៅរបស់គ្រូបង្រៀន និងនាយកសាលារៀនដែលបានចូលរួមក្នុងការសិក្សានេះ ដែលព័ត៌មានទាំងនេះរួមមានសមាសភាពគ្រូបង្រៀន និងនាយកសាលារៀនតាម ភេទ តួនាទី អាយុ និងមុខវិជ្ជាឯកទេស ត្រូវបានវិភាគ និងបង្ហាញដូចក្នុងតារាងខាងក្រោម។

តារាងអំពី តួនាទី និងភេទ

| | | តួនាទី | | សរុប |
|---|---|---|---|---|
| | | នាយក/នាយិកា | គ្រូបង្រៀន | |
| ភេទ | ប្រុស | ៦ | ៤៨ | ៥៤ |
| | ស្រី | ៣ | ១៩ | ២២ |
| សរុប | | ៩ | ៦៧ | ៧៦ |

តារាងទី១នេះបង្ហាញពីព័ត៌មានរបស់គ្រូបង្រៀន និងនាយកសាលារៀន ដែលបានចូលរួមនៅក្នុងការសិក្សា ទាក់ទងទៅនឹងតួនាទី និងភេទរបស់ពួកគាត់។ តាមលទ្ធផលបង្ហាញថា សមាសភាពគ្រូបង្រៀនមានចំនួន ៤៨នាក់ ក្នុងនោះស្រីចំនួន ១៩នាក់ និងនាយកសាលារៀនមានចំនួន ៦នាក់ និងនាយិកាចំនួន ៣នាក់។ សរុបមកអ្នកចូលរួមនៅក្នុងការសិក្សានេះ មានបុរសចំនួន ៥៤នាក់ ស្មើ៧១.១% ក្នុងនោះស្រីមានចំនួន ២២នាក់ ស្មើ២៨.៩%។

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវ ការវិភាគនិន្នន័យគឺប្រើប្រាស់កម្មវិធីវិភាគទិន្នន័យស្ថិតិ និងលទ្ធផលនៃការវិភាគត្រូវបានសរសេរតាមបែបស្ថិតិពណ៌នា និងស្ថិតិសន្និដ្ឋានដើម្បីគាំទ្រនូវការសន្និដ្ឋាននានា។ មុននឹងចាប់ផ្តើមវិភាគ អ្នកស្រាវជ្រាវត្រូវធ្វើការចងកូដសម្រាប់ចម្លើយនីមួយៗជាទម្រង់លេខ រួចបញ្ចូលទៅក្នុងកម្មវិធីស្ថិតិដើម្បីវិភាគ។ ការចងកូដចំពោះកម្រងសំណួរផ្នែកទីមួយ គឺតាមលំដាប់លំដោយពីលេខតូចទៅលេខធំ។

ឧទាហរណ៍ សំណួរទាក់ទងទៅនឹងភេទ ត្រូវតាងជា ១=ប្រុស និង២=ស្រី ជាដើម។ ចំពោះការតាងកូដសម្រាប់សំណួរផ្សេងៗទៀត គឺមានទម្រង់ប្រហាក់ប្រហែលគ្នា។

ទិន្នន័យដែលទទួលបានតាមរយៈការសម្ភាសន៍ និងការបំពេញកម្រងសំណួរ ត្រូវបានអ្នកស្រាវជ្រាវប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ SPSS ដើម្បីបញ្ចូល និងវិភាគទិនន្ន័យ និងប្រើប្រាស់កម្មវិធី Microsoft Excel សម្រាប់ការបង្កើតជាក្រាហ្វិក។ រាល់ចម្លើយដែលត្រូវធ្វើការវិភាគ គឺអាស្រ័យទៅលើប្រភេទសំណួរ ថាតើវាជាប្រភេទសំណួរបើក ឬសំណួរបិទ។ ក្នុងការវិភាគទិន្នន័យទាំងមូល អ្នកសិក្សាបានជ្រើសយកតែចំណុចសំខាន់ៗមួយចំនួនមកធ្វើការបកស្រាយបង្ហាញ ដូចជា ស្ថានភាពរបស់គ្រូបង្រៀននៅតាមតំបន់ ស្ថានភាពនៃរបាយគ្រូបង្រៀន ការអនុវត្តគោលការពង្រាយគ្រូកន្លងមក និងបញ្ហាប្រឈមនានា។ គ្រប់ចម្លើយដែលបានមកពីអ្នកចូលរួមនៅក្នុងកម្រងសំណួរ ត្រូវបានត្រួតពិនិត្យថាតើវាមានលក្ខណៈសមស្រប និងអាចយកជាការបាន ឬយ៉ាងណា ព្រមទាំងធ្វើការសម្អាតចម្លើយទាំងនោះ មុនពេលយកទិន្នន័យទាំងនោះបញ្ចូលក្នុងកុំព្យូទ័រធ្វើការវិភាគ។

រាល់ទនិន្ន័យទាំងអស់ដែលត្រូវបានធ្វើការវិភាគរួច ត្រូវបានទាញយកមកបង្ហាញ និងបកស្រាយទៅតាមគោលបំណងសំខាន់ៗនៃការសិក្សាស្រាវជ្រាវនេះ។ បន្ទាប់ពីបានលទ្ធផល និងការធ្វើការបកស្រាយពន្យល់រួច អ្នកស្រាវជ្រាវធ្វើការសន្និដ្ឋាន ព្រមទាំងធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងចំណោទបញ្ហាដែលបានលើកឡើងជាសំណួរស្រាវជ្រាវ និងគោលបំណងនៃការស្រាវជ្រាវនេះ ហើយធ្វើការសន្និដ្ឋាន និងវាយតម្លៃទៅលើទស្សនៈរបស់គ្រូបង្រៀន និងនាយកសាលារៀន។ អ្នកស្រាវជ្រាវក៏នឹងចូលរួមជាអនុសាសន៍ និងសំណូមពរមួយចំនួន ដល់ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈម និងលើកកម្ពស់ប្រសិទ្ធភាព នៃការបែងចែកថ្នាក់បណ្តុំមុខវិជ្ជាសិក្សាឱ្យបានសមស្របទៅនឹងការទស្សនៈយល់ឃើញរបស់គ្រូបង្រៀន និងនាយកសាលារៀន ទៅនឹងស្ថានភាពជាក់ស្តែង។

## ៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ

ក្រមសីលធម៌ ពិតជាចាំបាច់ណាស់សម្រាប់អ្នកសិក្សាស្រាវជ្រាវ អ្នកចូលរួម និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ដោយឡែក ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានរក្សានូវក្រមសីលធម៌មួយយ៉ាងច្បាស់លាស់ ក្នុងគោលបំណង គោរព ផ្ដល់តម្លៃដល់អ្នកចូលរួមទាំងអស់ ព្រមទាំងទិន្នន័យមានភាពជឿជាក់ និងអាចទទួលយកបាន។ ដើម្បីរក្សាបាននូវក្រមសីលធម៌ អ្នកស្រាវជ្រាវ បានទទួលលិខិតអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីសុំការអនុញ្ញាត ក្នុងការចុះទៅក្រុង-ស្រុកគោលដៅទាំង ៥។ បន្ទាប់មកទៀតអ្នកស្រាវជ្រាវបានសុំការអនុញ្ញាតពីប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង-ស្រុក ដើម្បីចុះទៅតាមសាលាក្នុងស្រុកនីមួយៗ និងបានសុំការអនុញ្ញាតដើម្បីបំពេញកម្រងសំណួរ សម្រាប់គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូ។ អ្នកស្រាវជ្រាវបាន ធ្វើការបង្ហាញពីគោលបំណង នៃការសិក្សាស្រាវជ្រាវនេះ និងបានពន្យល់នូវរាល់ខ្លឹមសារនៃសំនួរនីមួយៗក្នុងកម្រងសំណួរ។ ទន្ទឹមគ្នានេះដែររាល់មុនការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវតែងតែជម្រាបអ្នកចូលរួម អំពីក្រមសីលធម៌របស់ការសិក្សាស្រាវជ្រាវ ដែលរក្សាការសម្ងាត់ចំពោះរាល់ចម្លើយរបស់អ្នកចូលរួម ដែលមិនបង្ហាញនូវអត្តសញ្ញាណឡើយ ហើយរាល់ព័ត៌មានទាំងឡាយដែលបានផ្ដល់ឱ្យ គឺត្រូវបានប្រើប្រាស់សម្រាប់តែការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះប៉ុណ្ណោះដើម្បីបំពេញលក្ខខ័ណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៧-២០១៩ ហើយរាល់ព័ត៌មានទាំងអស់ត្រូវបានរក្សាជាការសម្ងាត់។ កម្រងសំណួរ និងចម្លើយដែលបានមកពីកម្រងសំណួរ ត្រូវបានប្រើប្រាស់សម្រាប់តែការសរសេរនិក្ខេបបទនេះតែម្យ៉ាងគត់។ អ្នកចូលរួមគ្រប់រូប អាចមានសិទ្ធិពេញលេញ ក្នុងការបដិសេធ មិនឆ្លើយសំណួរណាមួយ ឬបញ្ឈប់ការចូលរួមក្នុងការបំពេញកម្រងសំណួរនេះបាន ដោយមិនមានបញ្ហាអ្វីឡើយ។ ម៉្យាងទៀត អ្នកស្រាវជ្រាវមិនបានធ្វើការថតសំឡេង ឬកត់ឈ្មោះអ្នកចូលរួម នៅក្នុងកម្រងសំណួរ ដើម្បីបានអត្តសញ្ញាណអ្នកផ្ដល់ចម្លើយឡើយ។

# ជំពូកទី៤

# លទ្ធផលនៃការស្រាវជ្រាវ

## លទ្ធផលនៃការស្រាវជ្រាវ

នៅក្នុងជំពូកទី៤នេះ នឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ពាក់ព័ន្ធជាមួយនឹងទស្សនៈរបស់លោកគ្រូ អ្នកគ្រូ និងនាយកសាលារៀនកម្រិតទុតិយភូមិ នៅក្នុងខេត្តកំពង់ចាម។ លទ្ធផលវិភាគនឹងត្រូវរៀបចំដូចខាងក្រោម៖

(១) លទ្ធផលនៃការវិភាគដែលត្រូវរៀបចំតាមលំដាប់លំដោយដូចខាងក្រោម៖

ក. លទ្ធផលនៃការវិភាគពីទស្សនៈរបស់គ្រូបង្រៀន និងនាយកសាលារៀន
ខ. លទ្ធផលនៃការវិភាគលើទស្សនៈរបស់គ្រូបង្រៀន
គ. លទ្ធផលនៃការវិភាគលើទស្សនៈរបស់នាយកសាលារៀន
ឃ. លទ្ធផលនៃការវិភាគលើទស្សនៈទូទៅនៃការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជា

(២) ការពិភាក្សា

ក. វត្ថុបំណងនៃការស្រាវជ្រាវ

## ៤.១ ទស្សនៈចំពោះការយល់ឃើញរបស់នាយក និងគ្រូបង្រៀន

ក្រាហ្វិកទី១៖ ការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សារបស់សិស្សានុសិស្ស




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកទី១ បង្ហាញថា នាយក និងនាយិកាយល់ថាសិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្រ្តពិតច្រើនជាងថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្រ្តសង្គម។ ចំណែកឯគ្រូបង្រៀនមានទស្សនៈថា សិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្រ្តសង្គមច្រើនជាងថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្រ្តពិត។ ទោះបីជាយ៉ាងណាក៏ដោយ ទស្សនៈដែលយល់ថាសិស្សានុសិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្រ្តសង្គម មានភាគរយច្រើនជាងថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្រ្តពិត គឺមានចំនួន៥៩.២% ចំណែកថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្រ្តពិតមានចំនួន៤០.៨% ប៉ុណ្ណោះ ដែលស្របទៅនឹងនិន្នាការនៃការចុះឈ្មោះចូលរៀនកម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្រ្តសង្គមរហូតដល់ជាង៦៤% នាឆ្នាំសិក្សា ២០១៨-២០១៩ នេះ ប៉ុន្តែវាមានទិសដៅផ្ទុយស្រលះពីគោលនយោបាយរបស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដែលចង់ឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសអភិវឌ្ឍន៍ត្រឹមឆ្នាំ ២០៥០ ដែលទាមទារឱ្យការអប់រំត្រូវផ្តោតសំខាន់លើផ្នែកវិទ្យាសាស្រ្តដើម្បីអាចក្លាយជាអ្នកផលិតនាពេលអនាគតបាន។

## ៤.២ ទស្សនៈនៃការយល់ឃើញរបស់គ្រូបង្រៀន

### ៤.២.១ ការជ្រើសរើសតាមចំណូលចិត្តរបស់សិស្ស

ក្រាហ្វិកទី១៖ ទស្សនៈចំពោះការជ្រើសរើសបណ្តុំមុខវិជ្ជាតាមចំណូលចិត្តរបស់សិស្ស




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកទី១ បង្ហាញថា គ្រូបង្រៀន៨០.៦% យល់ថាសិស្សជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាដោយខ្លួនឯង ខណៈមានគ្រូចំនួន៧.៤៦% មិនយល់ថាសិស្សជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាតាមចំណូលចិត្តរបស់ខ្លួនទេ ចំណែកគ្រូបង្រៀនចំនួន១១.៩៤% ឆ្លើយថាមិនដឹង។ តាមរយៈទិន្នន័យនេះបង្ហាញថា សិស្សភាគច្រើនបានជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សានៅកម្រិតទុតិយភូមិដោយការចូលចិត្តរបស់ខ្លួនឯង។

### ៤.២.២ ការជ្រើសរើសតាមឪពុកម្តាយ

ក្រាហ្វិកទី២៖ ទស្សនចំពោះការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាតាមឪពុកម្តាយ




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកទី២ បង្ហាញឱ្យឃើញថា មានគ្រូបង្រៀនចំនួន១៦.៤២% យល់ស្របថាសិស្សជ្រើសរើសបណ្តុំមុខវិជ្ជាតាមឪពុកម្តាយ ប៉ុន្តែមានគ្រូបង្រៀនចំនួនរហូតដល់៤៤.៧៨% មិនយល់ស្របដូចនេះទេ និងគ្រូបង្រៀនចំនួន៣៨.៧១%ឆ្លើយថាមិនដឹង។ ដូចនេះតាមលទ្ធផលនេះបានបញ្ជាក់ថា ឪពុកម្តាយភាគច្រើនមិនបានសម្រេចចិត្តជំនួសកូនៗ ដើម្បីជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាសម្រាប់កូនរបស់ពួកគាត់ទេ។

### ៤.២.៣ ការជ្រើសរើសតាមលំដាប់ពិន្ទុនៃមុខវិជ្ជា

ក្រាហ្វិកទី៣៖ ទស្សនចំពោះការជ្រើសរើសតាមលំដាប់ពិន្ទុនៃមុខវិជ្ជា




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

ការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាតាមលំដាប់ពិន្ទុមុខវិជ្ជាគឺសំដៅដល់ការជ្រើសរើសដោយអាស្រ័យលើពិន្ទុមុខវិជ្ជាវិទ្យាសាស្ត្រដូចជា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា ឬមុខវិជ្ជាវិទ្យាសាស្ត្រសង្គមដូចជា ភាសាខ្មែរ ប្រវត្តិវិទ្យា ភូមិវិទ្យា និងពលរដ្ឋវិទ្យាជាដើម។ តាមក្រាហ្វិកបង្ហាញថា គ្រូបង្រៀនចំនួន៥២.២៤% យល់ស្របថាសិស្សានុសិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាទៅតាមពិន្ទុនៃមុខវិជ្ជា ចំណែកគ្រូបង្រៀនចំនួន២០.៩% ឆ្លើយមិនដឹង ប៉ុន្តែមានគ្រូបង្រៀនចំនួន២៦.៨៧% មិនយល់ស្របនឹងទស្សនៈខាងលើនេះទេ។ តាមរយៈលទ្ធផលបង្ហាញខាងលើនេះ អាចឱ្យអ្នកស្រាវជ្រាវសន្និដ្ឋានថា ភាគច្រើនសិស្សានុសិស្សបានជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាដោយផ្តោតទៅលើពិន្ទុតាមមុខវិជ្ជាដែលពួកគេទទួលបាន និងគិតថាពួកគេពូកែលើមុខវិជ្ជាទាំងនោះ។

### ៤.២.៤ តាមមធ្យមភាគនៃការប្រឡង

ក្រាហ្វិកទី៩៖ ទស្សនៈការជ្រើសរើសតាមមធ្យមភាគនៃការប្រឡង




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញថា គ្រូបង្រៀនចំនួនដល់៥០.៧៥% យល់ស្របថាសិស្សជ្រើសរើសបណ្ដុំមុខវិជ្ជាសិក្សាតាមរយៈមធ្យមភាគដែលពួកគេទទួលបាន និងគ្រូបង្រៀនចំនួន១៩.៤% មិនយល់ស្របនឹងទស្សនៈនេះទេ ចំណែកគ្រូបង្រៀនចំនួន២៩.៨៥% បានជ្រើសរើសយកអព្យាក្រឹត។ ដូចដែលលទ្ធផលបង្ហាញថា គ្រូបង្រៀនគិតថាសិស្សានុសិស្សភាគច្រើនអាចជ្រើសរើសថ្នាក់បណ្ដុំមុខវិជ្ជាសិក្សាដោយមូលហេតុថា ពួកគេទទួលបានកម្រិតមធ្យមភាគខ្ពស់ ឬល្អប្រសើរសម្រាប់ការសិក្សានាឆ្នាំកន្លងទៅ ដែលជាទុនសម្រាប់ឱ្យពួកគេអាចសម្រេចចិត្តបានត្រឹមត្រូវក្នុងការជ្រើសរើសថ្នាក់បណ្ដុំមុខវិជ្ជាសិក្សា។

## ៤.២.៥ តាមការប្រឹក្សាយោបល់

ក្រាហ្វិកទី៥៖ទស្សនចំពោះការជ្រើសរើសតាមរយៈការប្រឹក្សាយោបល់




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

ក្រាហ្វិកទី៥បង្ហាញថា តាមទស្សនៈរបស់គ្រូបង្រៀនយល់ឃើញថាសិស្សានុសិស្សភាគច្រើនបានជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាណាមួយ ក៏ព្រោះតែបានទទួលការប្រឹក្សាយោបល់ពីគ្រូបង្រៀន ឪពុកម្តាយ ឬអ្នកប្រឹក្សាយោបល់ដែលមានបទពិសោធន៍ច្បាស់លាស់ ប៉ុន្តែមានសិស្សភាគតិចប៉ុណ្ណោះដែលសម្រេចចិត្តចូលរៀន ថ្នាក់បណ្តុំមុខវិជ្ជាសិក្សាដោយមិនបានទទួលការប្រឹក្សាយោបល់។ តាមរយៈលទ្ធផលនេះបង្ហាញបានថា មានគ្រូបង្រៀនចំនួន ៥៦.៧២% យល់ស្របថាសិស្សចូលរៀននៅ ថ្នាក់បណ្តុំមុខវិជ្ជាណាមួយព្រោះពួកគេទទួលបានការប្រឹក្សាយោបល់ជាមុន តែមានគ្រូបង្រៀនចំនួន១៦.៤២% យល់ផ្ទុយពីទស្សនៈខាងលើនេះ និងមានគ្រូបង្រៀនចំនួន២៦.៨៧% បានជ្រើសរើសយកអព្យាក្រឹត។

## ៤.២.៦ តាមតម្រូវការទីផ្សារការងារ

ក្រាហ្វិកទី៦៖ ទស្សនចំពោះការជ្រើសរើសតាមតម្រូវការទីផ្សារការងារ




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកទី៦បានបង្ហាញឱ្យឃើញថា មានគ្រូបង្រៀនភាគច្រើនរហូតដល់៥៨.២១% យល់ស្របថា សិស្សានុសិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាគឺអាស្រ័យលើទីផ្សារការងារដែលពួកគេគិតថាមានតម្រូវការច្រើននាពេលបច្ចុប្បន្ន ឬការងារណាដែលនឹងមានសក្តានុពលនាពេលអនាគត ប៉ុន្តែក៏មានគ្រូបង្រៀនចំនួន២៥.៣៧% មិនយល់ស្របដូចមតិខាងលើនេះទេ ពួកគាត់យល់ថា សិស្សនុសិស្សមិនបានគិតទៅលើទីផ្សារការងារដែលពួកគេនឹងចាប់យកជាមុខរបរ ឬជាបណ្តុំមុខវិជ្ជាដែលជាប់ទាក់ទងទៅនឹងជំនាញសិក្សានៅមហាវិទ្យាល័យពេលបញ្ចប់ការសិក្សា ឬនិន្នាការការងារនាពេលអនាគតនោះទេ ចំណែកគ្រូបង្រៀន១៦.៤២% មានមតិមិនដូចទៅនឹងគំនិតទាំងពីរខាងលើនេះទេ។

## ៤.៣ ទស្សនៈនៃការយល់ឃើញរបស់នាយកសាលា

### ៤.៣.១ ការជ្រើសរើសតាមចំណូលចិត្តរបស់សិស្ស

ក្រាហ្វិកទី៧៖ ទស្សនៈចំពោះការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាតាមចំណូលចិត្ត




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញថា នាយក/នាយិកាដែលយល់ស្របចំពោះទស្សនៈដែលនិយាយថា សិស្សបានជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាតាមចំណង់ចំណូលចិត្តរបស់ពួកគេផ្ទាល់មានចំនួន៧៧.៧៨% ចំណែកឯអ្នកឆ្លើយថាមិនដឹងមានចំនួន២២.២២%។ តាមទិន្នន័យនេះយើងអាចមើលឃើញថា ទស្សនៈរបស់នាយក/នាយិកាចំពោះការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាតាមចំណូលចិត្តរបស់ខ្លួនគឺស្របទៅនឹងការយល់ឃើញរបស់គ្រូបង្រៀន។

### ៤.៣.២ ការជ្រើសរើសតាមឪពុកម្តាយ

ក្រាហ្វិកទី៨៖ ទស្សនៈចំពោះការជ្រើសរើសបណ្តុំមុខមុខវិជ្ជាសិក្សាតាមឪពុកម្តាយ




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញឱ្យឃើញថា មាននាយក/នាយិកាចំនួន៣៣.៣៣% យល់ស្របថា សិស្សានុសិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាតាមឪពុកម្តាយរបស់ខ្លួន ចំណែក ២២.២២% ជ្រើសរើសយកមតិអព្យាក្រឹត ប៉ុន្តែមានទស្សនៈរហូតដល់៤៤.៤៤% មិនយល់ស្រប ថា ការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាតាមឪពុកម្តាយនោះទេ។ តាមលទ្ធផលរបស់ ទិន្នន័យខាងលើនេះបង្ហាញថា ទស្សនៈរបស់នាយក/នាយិកាគឺស្របទៅនឹងទស្សនៈរបស់គ្រូ បង្រៀនដែលយល់ឃើញថា ការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាតាមរយៈឪពុកម្តាយមិន មែនជាជំរើសសម្រាប់សិស្សានុសិស្សចង់បាននោះទេ។

### ៤.៣.៣ ការជ្រើសតាមលំដាប់ពិន្ទុនៃមុខវិជ្ជា

ក្រាហ្វិកទី៩៖ ទស្សនៈចំពោះការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាតាមលំដាប់ពិន្ទុនៃមុខវិជ្ជា




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញថា មាននាយក/នាយិការហូតដល់៦៦.៦៧% យល់ស្របនឹងទស្សនៈដែលនិយាយថា សិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាតាមលំដាប់ពិន្ទុនៃមុខវិជ្ជាសិក្សា ចំណែកអ្នកចូលរួមចំនួន២២.២២% បានជ្រើសរើសយកអព្យាក្រឹត និងមានអ្នកចូលរួមចំនួន ១១.១១% មិនយល់ស្របនឹងទស្សនៈខាងលើនេះទេ។ តាមរយៈលទ្ធផលខាងលើនេះ នាយកសាលា និងគ្រូបង្រៀនមានការយល់ឃើញដូចគ្នាថា សិស្សានុសិស្សភាគច្រើនបានជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាគឺអាស្រ័យទៅលើពិន្ទុនៃមុខវិជ្ជានីមួយៗដែលមានលំដាប់ខ្ពស់ជាងគេ ជាពិសេសគឺមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា ឬគីមីវិទ្យាសម្រាប់ថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ និងមុខវិជ្ជាភាសាខ្មែរ ភូមិវិទ្យា ប្រវត្តិវិទ្យា ឬពលរដ្ឋវិទ្យាសម្រាប់ថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម។

### ៤.៣.៤ ការជ្រើសរើសតាមមធ្យមភាគនៃការប្រឡង

ក្រាហ្វិកទី១០៖ ទស្សនៈចំពោះការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាតាមមធ្យមភាគ




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញថា មាននាយក/នាយិកាចំនួន៣៣.៣៣% យល់ស្របថាការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សារបស់សិស្សគឺតាមរយៈមធ្យមភាគនៃការប្រឡងប្រចាំឆ្នាំ ចំណែកអ្នកចូលរួមចំនួន៤៤.៤៤% បានជ្រើសរើសយកអព្យាក្រឹត និងមានអ្នកចូលរួមចំនួន២២.២២% មានគំនិតមិនយល់ស្របទេ។ លទ្ធផលនេះបានសបញ្ជាក់ឱ្យឃើញថា នាយកសាលាបានគិតថាមធ្យមភាគប្រចាំឆ្នាំរបស់សិស្សមិនមានឥទ្ធិពលដល់ការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សានោះទេ ទោះយ៉ាងណាទស្សនៈនេះមានភាពផ្ទុយគ្នារវាងទស្សនៈរបស់គ្រូបង្រៀនដែលយល់ឃើញថា មធ្យមភាគប្រចាំឆ្នាំរបស់សិស្សានុសិស្សក៏ជាចំណែកដ៏សំខាន់ដល់ការសម្រេចចិត្តជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាផងដែរ។

### ៤.៣.៥ ការជ្រើសរើសតាមការប្រឹក្សាយោបល់

ក្រាហ្វិកទី១១៖ ទស្សនៈចំពោះការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាតាមការប្រឹក្សាយោបល់




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញថា មាននាយក/នាយិកាចំនួន៧៧.៧៨% បានយល់ស្របនឹងគំនិតថា សិស្សានុសិស្សបានជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាតាមរយៈទទួលបានការប្រឹក្សាយោបល់ពីអ្នកដទៃ ចំណែកអ្នកចូលរួមចំនួន២២.២២% បានជ្រើសរើសអព្យាក្រឹត និងមិនមានអ្នកមានគំនិតមិនយល់ស្របទេ។ ដូចដែលលទ្ធផលបានបង្ហាញខាងលើ នាយកសាលា និងគ្រូបង្រៀនមានគំនិតប្រហាក់ប្រហែលគ្នា គឺការផ្តល់ប្រឹក្សាដល់សិស្ស ឬការទទួលបានការប្រឹក្សារបស់សិស្សមុនពេលចូលរៀនថ្នាក់បណ្តុំមុខវិជ្ជាសិក្សាពីគ្រូបង្រៀន ឬអ្នកមានបទពិសោធលើវិស័យអប់រំ ជាកត្តាដ៏សំខាន់ក្នុងការជំរុញទឹកចិត្តសិស្សានុសិស្សឱ្យជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាដែលត្រឹមត្រូវ សមស្របទៅតាមសមត្ថភាព ចំណង់ចំណូលចិត្ត និងតម្រូវការរបស់ពួកគេនាពេលអនាគតថែមទៀតផង។

## ៤.៣.៦ ការជ្រើសរើសតាមតម្រូវការទីផ្សារការងារ

ក្រាហ្វិកទី១២៖ ទស្សនៈចំពោះការជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាតាមតម្រូវការទីផ្សារ




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញឱ្យឃើញថា នាយកសាលារៀនទាំងអស់យល់ស្របនឹងគំនិតថា សិស្សានុសិស្សជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សា គឺតាមតម្រូវការទីផ្សារការងារ។ តាមរយៈលទ្ធផលដែលបានពីទិន្នន័យបង្ហាញថា នាយកសាលារៀន និងគ្រូបង្រៀនមានគំនិតដូចគ្នា ដោយយល់ថា តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងការងារដែលមានតម្រូវការខ្ពស់នាពេលអនាគត គឺជាចំណែកដ៏សំខាន់ក្នុងការជំរុញសិស្សានុសិស្សឱ្យជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាណាមួយដែលពួកគេពេញចិត្ត។

## ៤.៤ ទស្សនៈទូទៅនៃការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជា

### ៤.៤.១ ទស្សនៈនៃការបែងចែកថ្នាក់រៀន

ក្រាហ្វិកទី១៣៖ ទស្សនៈចំពោះកម្រិតថ្នាក់គួរបែងចែកថ្នាក់បណ្តុំមុខវិជ្ជាសិក្សា




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញថា នាយក/នាយិកាមានទស្សនៈចង់ឱ្យមានការបែងចែកថ្នាក់បណ្តុំមុខវិជ្ជាសិក្សាចាប់ពីកម្រិតថ្នាក់ទី១០ មានចំនួន៥៥.៥៦% ចំណែកឯគ្រូបង្រៀនមានទស្សនៈដូចគ្នានេះមានចំនួន២៥.៣៧%។ ចំពោះទស្សនៈដែលចង់ឱ្យមានការបែងចែកថ្នាក់រៀននៅកម្រិតថ្នាក់ទី១១ មាននាយក/នាយិកាចំនួន៤៤.៤៤% ចំណែកឯគ្រូបង្រៀនមានចំនួនដល់៥៥.៥២% បានបង្ហាញមតិយល់ស្រប។ ប៉ុន្តែនៅកម្រិតថ្នាក់ទី១២ មានតែគ្រូបង្រៀនចំនួន១៦.៤២% ប៉ុណ្ណោះដែលបង្ហាញមតិយល់ស្រប និងការបែងចែកចាប់ពីថ្នាក់បឋមភូមិមានគ្រូបង្រៀនចំនួន ២.៩៩% នៃអ្នកចូលរួមបានយល់ស្រប។ តាមទិន្នន័យបានបង្ហាញថា តាមទស្សនៈរបស់នាយកសាលារៀនភាគច្រើនគឺ ចង់ឱ្យមានការបែងចែកថ្នាក់រៀនចាប់ពីកម្រិតថ្នាក់ទី១០ឡើងទៅ ចំណែកឯតាមទស្សនៈរបស់គ្រូបង្រៀនភាគច្រើនវិញបង្ហាញថា ការបែងចែកថ្នាក់រៀនគួររៀបចំចាប់ពីថ្នាក់ទី១១ ឡើងទៅ។

ក្រាហ្វិកទី១៨៖ ទស្សនៈចំពោះការបែងចែកថ្នាក់តាមការស្ម័គ្រចិត្ត




ប្រភព៖លទ្ធផលបានពីកម្រងសំណួរខែមិថុនាឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញថា ទស្សនៈនៃការបែងចែកថ្នាក់បណ្ដុំមុខវិជ្ជាសិក្សាដល់សិស្សានុសិស្សតាមការស្ម័គ្រចិត្តមានលក្ខណៈមិនដូចគ្នាទេ ទាំងការយល់ឃើញរបស់នាយកសាលារៀន និងការយល់ឃើញរបស់គ្រូបង្រៀន សម្រាប់នាយក/នាយិកាចំនួន២២.២២% យល់ថាវិធីសាស្ត្រនេះល្អ ចំណែង៣៣.៣៣% យល់ថាល្អបង្គួរ មានយកសាលារៀនចំនួន ២២.២២% យល់ថាមធ្យម និង២២.២២%ផ្សេងទៀត យល់ថាមិនល្អ។ ចំពោះទស្សនៈរបស់គ្រូបង្រៀនវិញបានបង្ហាញថា វិធីសាស្ត្រនេះមានគ្រូបង្រៀនចំនួន១៩.៤០%ប៉ុណ្ណោះ យល់ថាល្អ ១៦.៤២% យល់ថាល្អបង្គួរ ១៦.៤២% យល់ថាមធ្យម និងគ្រូបង្រៀនរហូតដល់ចំនួន៤៧.៧៦% យល់ថាមិនល្អ។ ដូចនេះអ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា ការបែងចែកថ្នាក់បណ្ដុំមុខវិជ្ជាសិក្សាតាមការស្ម័គ្រចិត្តរបស់សិស្សដូចនាពេលបច្ចុប្បន្ននេះ មិនទាន់មានភាពល្អប្រសើរនោះទេបើតាមទស្សនៈរបស់គ្រូបង្រៀនភាគច្រើនដែលបានចូលរួមក្នុងការស្រាវជ្រាវ។ ចំណែកឯនាយកសាលារៀនវិញ មានទស្សនៈថាការបែងចែកថ្នាក់តាមវិធីសាស្ត្រនេះគឺ មានភាពល្អបង្គួរដែលត្រូវមានការកែលម្អបន្ថែមនាពេលអនាគត។

ក្រាហ្វិកទី១៥៖ ទស្សនៈចំពោះការបែងចែកថ្នាក់ទៅតាមមុខវិជ្ជា




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញថា ទស្សនៈនៃការបែងចែកថ្នាក់បណ្តុំមុខវិជ្ជាសិក្សាសម្រាប់សិស្សានុសិស្ស ដោយការបែងចែកថ្នាក់រៀនទៅតាមមុខវិជ្ជាមានការយល់ឃើញប្រហាក់ប្រហែលគ្នារវាងនាយកសាលារៀន និងគ្រូបង្រៀន ដោយក្នុងនោះមាននាយក/នាយិកាចំនួន ៤៤.៤៤% យល់ថាវិធីសាស្រ្តនេះល្អ មាននាយកសាលារៀនចំនួន២២.២២% យល់ថាល្អបង្គួរ ២២.២២% យល់ថាមធ្យម និង១១.១១%ផ្សេងទៀត យល់ថាមិនល្អ។ ចំណែកឯគ្រូបង្រៀនចំនួន៤៣.២៨% យល់ថាការប្រើប្រាស់វិធីសាស្រ្តនេះល្អ គ្រូបង្រៀនចំនួន២៩.៨៥%ទៀតយល់ថាល្អបង្គួរ ឯគ្រូបង្រៀន៨.៩៦% យល់ថាមធ្យម និងគ្រូបង្រៀនចំនួន១៧.៩១% យល់ថាមិនល្អ។ តាមរយៈលទ្ធផលខាងលើបង្ហាញថា បើតាមទស្សនៈរបស់គ្រូបង្រៀន និងនាយកសាលាភាគច្រើនគឺ ចង់ឱ្យមានការបែងចែកថ្នាក់រៀនទៅតាមមុខវិជ្ជាសិក្សារបស់សិស្សដូចជាថ្នាក់រៀនមុខវិជ្ជាភាសាខ្មែរ ថ្នាក់រៀនមុខវិជ្ជាគណិតវិទ្យា ឬថ្នាក់រៀនមុខវិជ្ជាភាសាបរទេសជាដើម ដើម្បីឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អកាន់តែប្រសើរឡើង។

ក្រាហ្វិកទី១៦៖ ទស្សនៈចំពោះការបែងចែកថ្នាក់តាមសមត្ថភាពរបស់សិស្ស




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញថា ទស្សនៈក្នុងការបែងចែកថ្នាក់រៀនទៅតាមសមត្ថភាពរបស់សិស្សមានការយល់ឃើញប្រហាក់ប្រហែលគ្នារវាងនាយកសាលារៀន និងគ្រូបង្រៀន សម្រាប់ទស្សនៈរបស់នាយក/នាយិកាចំនួន៥៥.៥៥% យល់ថាការប្រើប្រាស់វិធីសាស្ត្រនេះល្អ មាននាយកសាលាចំនួន២២.២២% យល់ថាល្អបង្គួរ ១១.១១% យល់ថាមធ្យម និង១១.១១% យល់ថាមិនល្អ។ ចំណែកទស្សនៈរបស់គ្រូបង្រៀនចំនួន៤៧.៧៦% យល់ថាការប្រើប្រាស់វិធីសាស្ត្របែងចែកថ្នាក់រៀននេះគឺល្អ ១៩.៤០% យល់ថាល្អបង្គួរ ១០.៤៥% យល់ថាមធ្យម និង ២២.៣៩% យល់ថាមិនល្អ។ តាមរយៈលទ្ធផលខាងលើអាចឱ្យអ្នកស្រាវជ្រាវសន្និដ្ឋានបានថា ទស្សនៈរបស់នាយកសាលារៀន និងគ្រូបង្រៀនភាគច្រើនយល់ស្របទៅនឹងវិធីសាស្ត្របែងចែកថ្នាក់រៀនទៅតាមសមត្ថភាពរបស់សិស្ស ដោយបែងចែកជាថ្នាក់សិស្សពូកែ ថ្នាក់សិស្សមធ្យម និងថ្នាក់សិស្សខ្សោយ ដើម្បីឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ។

## ៤.៤.២ ទស្សនៈចំពោះការតម្រង់ទិសសិស្សឱ្យជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាបានត្រឹមត្រូវ

ក្រាហ្វិកទី១៧៖ ទស្សនៈនាយក និងគ្រូបង្រៀនចំពោះការតម្រង់ទិសសិស្សឱ្យជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាបានត្រឹមត្រូវ




ប្រភព៖ លទ្ធផលបានពីកម្រងសំណួរ ខែមិថុនា ឆ្នាំ២០១៩

តាមក្រាហ្វិកបង្ហាញថា បើតាមទស្សនៈរបស់គ្រូបង្រៀន និងនាយកសាលារៀនដែលបានចូលរួមឆ្លើយសំណួរក្នុងការស្រាវជ្រាវ ចំពោះទស្សនៈក្នុងការជួយតម្រង់ទិសសិស្សឱ្យជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាបានត្រឹមត្រូវ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

ទស្សនៈចំពោះការផ្តល់ប្រឹក្សាដល់សិស្សម្នាក់ៗ មាន៤៣%

ទស្សនៈចំពោះការផ្តល់ការណែនាំជារួម មាន៨២%

ទស្សនៈចំពោះការណែនាំពេលគោរពទង់ជាតិ មាន៩១%

ទស្សនៈចំពោះការបញ្ច្រៀបព័ត៌មានពេលកំពុងបង្រៀន មាន៦១%

ទស្សនៈចំពោះការបង្កើតក្រុមប្រឹក្សាដើម្បីជួយដល់សិស្ស មាន២៥%

ទស្សនៈចំពោះការប្រឹក្សាណែនាំដល់អាណាព្យាបាលសិស្ស មាន៤២%

ទស្សនៈចំពោះការប្រឡងជ្រើសរើសសិស្ស មាន៣៨%

ទស្សនៈចំពោះការប្រឡងជ្រើសរើសតែលើមុខវិជ្ជា គណិតវិទ្យា និងភាសាខ្មែរ ២៩%

ទស្សនៈចំពោះការប្រឡងជ្រើសរើសតែលើមុខវិជ្ជាវិទ្យាសាស្ត្រ មាន១៣%

តាមរយៈលទ្ធផលដែលបានបង្ហាញខាងលើនេះ អាចឱ្យអ្នកស្រាវជ្រាវបានដឹងថា នាយកសាលារៀន និងគ្រូបង្រៀនភាគច្រើនចង់ឱ្យមាន ការផ្ដល់ការណែនាំជារួមដល់សិស្សានុសិស្សអំពីបណ្ដុំមុខវិជ្ជាសិក្សាដែលពួកគេគួរជ្រើសរើសដើម្បីចូលរៀននៅកម្រិតថ្នាក់មធ្យមសិក្សាទុតិយភូមិ ដែលមានការគាំទ្រចំពោះទស្សនៈនេះរហូតដល់៨២% នៃអ្នកចូលរួមទាំងអស់។ ទោះបីជាយ៉ាងណាក៏ដោយ ទស្សនៈចំពោះការប្រឡងជ្រើសរើសតែលើមុខវិជ្ជាវិទ្យាសាស្ត្រ មានអ្នកចូលរួមតែ១៣%ប៉ុណ្ណោះដែលគាំទ្រចំពោះវិធីសាស្ត្រនេះ។

## ៤.៥ បញ្ហាប្រឈមនៃការជ្រើសរើសថ្នាក់បណ្ដុំមុខវិជ្ជាសិក្សា

### ៤.៥.១ កម្រិតសាលារៀន

- គ្មានការជ្រើសរើសឱ្យបានត្រឹមត្រូវរវាងសិស្សរៀននៅថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រពិត
- ការបែងចែកថ្នាក់បណ្ដុំមុខវិជ្ជាសិក្សានីមួយៗ មានវិសមភាពដោយសារនិន្នាការនៃសិស្សដែលចង់ប្រឡងជាប់សញ្ញាបត្រទុតិយភូមិ
- មានការលំបាកក្នុងការបែងចែកភារកិច្ចគ្រូបង្រៀន ដោយសារម៉ោងបង្រៀនមិនស្មើគ្នារវាងថ្នាក់បណ្ដុំមុខវិជ្ជាសិក្សានីមួយៗ។

### ៤.៥.២ គ្រូបង្រៀន

- គ្រូមុខវិជ្ជាវិទ្យាសាស្ត្របង្រៀនមិនដិតដល់ ចំពោះថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម
- គ្រូមុខវិជ្ជាវិទ្យាសាស្ត្រសង្គមបង្រៀនមិនដិតដល់ ចំពោះថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ
- គ្រូបង្រៀនមុខវិជ្ជាមិនប្រឡង មិនទទួលបានការយកចិត្តទុកដាក់រៀនពីសិស្សានុសិស្ស
- គ្រូបង្រៀនមិនទាន់យល់ច្បាស់ពីការបែងចែកថ្នាក់បណ្តុំមុខវិជ្ជាសិក្សានីមួយៗ នាំឱ្យខ្វះការលើកទឹកចិត្តដល់សិស្សានុសិស្ស
- គ្រូបង្រៀនធ្វើបុរេវិនិច្ឆ័យចំពោះសមត្ថភាពសិស្សដែលរៀនថ្នាក់បណ្តុំមុខវិជ្ជាសិក្សានីមួយៗ។

### ៤.៥.៣ សិស្ស

- មិនខិតខំរៀនសូត្រ ចំពោះមុខវិជ្ជាមិនប្រឡង
- ជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សានីមួយៗតាមគ្នា
- មិនយល់ពីការជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សានីមួយៗ
- មានភាពរើសអើងចំពោះថ្នាក់បណ្តុំមុខវិជ្ជាសិក្សាផ្សេងគ្នា
- រៀននៅថ្នាក់បណ្តុំមុខវិជ្ជាសិក្សាណាដែលគិតថាងាយនឹងប្រឡងជាប់
- សិស្សានុសិស្សដែលរៀនក្នុងថ្នាក់បណ្តុំមុខវិជ្ជាសិក្សាវិទ្យាសាស្ត្រសង្គម មិនខិតខំរៀនសូត្រមុខវិជ្ជាវិទ្យាសាស្ត្រពិត
- សិស្សានុសិស្សដែលរៀនក្នុងថ្នាក់បណ្តុំមុខវិជ្ជាសិក្សាវិទ្យាសាស្ត្រពិត មិនខិតខំរៀនសូត្រមុខវិជ្ជាវិទ្យាសាស្ត្រសង្គម។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

### ៥.១ សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវ ការវិភាគ និងលទ្ធផលនៃការស្រាវជ្រាវទៅលើប្រធានបទ "ទស្សនៈរបស់គ្រូ និងនាយកសាលាក្នុងការតម្រង់ទិសសិស្សឱ្យជ្រើសរើសមុខវិជ្ជាសិក្សានៅមធ្យមសិក្សាទុតិយភូមិ ត្រូវទៅនឹងតម្រូវការរបស់ខ្លួន" អ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា ទស្សនៈរបស់គ្រូបង្រៀន និងនាយកសាលាចំពោះការតម្រង់ទិសសិស្សឱ្យជ្រើសរើសបណ្តុំមុខវិជ្ជាសិក្សាគឺលទ្ធផលបង្ហាញថា គ្រូបង្រៀន និងនាយកសាលាចង់ឱ្យប្រើប្រាស់វិធីសាស្ត្រការណែនាំសិស្សជារួម មានភាគរយខ្ពស់ជាងគេ រហូតដល់៨២% នៃអ្នកចូលរួមទាំងអស់ ចំណែកឯវិធីសាស្ត្រក្នុងការបែងចែកសិស្ស តាមរយៈការប្រឡងជ្រើសរើសទៅលើតែមុខវិជ្ជាវិទ្យាសាស្ត្រ គឺមានភាគរយទាបជាងគេត្រឹមតែ១៣%តែប៉ុណ្ណោះ នេះបញ្ជាក់ឱ្យឃើញថាទាំងគ្រូបង្រៀន និងនាយកសាលាចង់ឱ្យមានការប្រើប្រាស់វិធីសាស្ត្រដោយប្រយោលតាមរយៈការផ្តល់ជាយោបល់ ឬការណែនាំដល់សិស្សានុសិស្សសម្រាប់ពួកគេមានសេរីភាពអាចសម្រេចចិត្តដោយខ្លួនឯងផ្ទាល់ដោយស្របទៅនឹងចំណង់ចំណូលចិត្ត ឬស្របតាមតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគតរបស់សង្គមជាតិ ជាជាងវិធីសាស្ត្រដែលផ្តោតលើសមត្ថភាពរបស់សិស្ស តាមរយៈការប្រឡងវាស់ស្ទង់សមត្ថភាពដើម្បីរៀបចំសិស្សឱ្យត្រូវទៅតាមថ្នាក់បណ្តុំមុខវិជ្ជាសិក្សាបានត្រឹមត្រូវ។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការយល់ឃើញរបស់គ្រូបង្រៀន និងនាយកសាលារៀន ចំពោះទស្សនៈនៃការបែងចែកថ្នាក់បណ្តុំមុខវិជ្ជាសិក្សាបង្ហាញថា គ្រូបង្រៀន និងនាយកសាលារៀនគាំទ្រដល់វិធីសាស្ត្រនៃការបែងចែកថ្នាក់តាមសមត្ថភាពរបស់សិស្សដែលមានអ្នកយល់ស្របថាល្អរហូតដល់៥១.៦៦% ចំណែកអ្នកដែលយល់ថាមិនល្អមានតែ១៦.៧៥% ប៉ុណ្ណោះ។ ផ្ទុយមកវិញ ចំពោះទស្សនៈនៃការបែងចែកថ្នាក់តាមការស្ម័គ្រចិត្តរបស់សិស្សមានអ្នកយល់ស្របថាល្អតែ២០.៨១% តែប៉ុណ្ណោះ ចំណែកឯអ្នកមិនយល់ស្របថាល្អមានភាគរយច្រើនជាងគឺ៣៤.៩៩% នៃអ្នកដែលបានចូលរួមទាំងអស់។

## ៥.២ សំណូមពរ និងអនុសាសន៍

តាមលទ្ធផលនៃការស្រាវជ្រាវ បានបង្ហាញឱ្យឃើញថាតាមទស្សនៈរបស់គ្រូបង្រៀនកម្រិតទុតិយភូមិ និងនាយកសាលារៀន សិស្សានុសិស្សមានទំនោរចំពោះការរៀនថ្នាក់បណ្ដុះមុខវិជ្ជាវិទ្យាសាស្ត្រសង្គមជាងថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រពិត។ បន្ថែមជាងនេះទៅទៀតវិធីនៃការជួយតម្រង់ទិសសិស្សនៅមានកម្រិតនៅឡើយ មិនទាន់បានឆ្លើយតបពេញលេញទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា ក្នុងការកែប្រែប្រជាជនកម្ពុជា ឱ្យក្លាយជាអ្នកផលិត និងជាប្រទេសឧស្សាហកម្មនៅឆ្នាំ២០៥០ នៅឡើយទេ។ ដើម្បីឱ្យសិស្សានុសិស្សអាចជ្រើសរើសថ្នាក់បណ្ដុំមុខវិជ្ជាសិក្សាបានត្រឹមត្រូវ និងអាចរួមចំណែកដោះស្រាយបញ្ហាប្រឈមនានាដែលបានរកឃើញនៅក្នុងការស្រាវជ្រាវនេះ ស្របជាមួយគ្នានេះដែរក៏អាចជួយលើការតម្រង់ទិសនៃការសិក្សារបស់សិស្ស ប្រកបដោយប្រសិទ្ធភាព អ្នកស្រាវជ្រាវ សុំធ្វើការសំណូមពរ និងផ្ដល់ជាយោបល់ ដើម្បីជាគំនិតក្នុងការជួយដល់កំណែទម្រង់នៃវិស័យអប់រំ ដែលផ្ដោតសំខាន់ទៅលើគុណភាពបង្រៀន និងរៀន ព្រមទាំងលទ្ធផលសិក្សារបស់សិស្សនៅកម្រិតទុតិយភូមិដូចតទៅៈ

### ក្រសួងអប់រំ យុវជន និងកីឡា

- បង្កើតលិខិតបទដ្ឋានគតិយុត្តិនានាដែលជួយដល់ការរៀបចំថ្នាក់បណ្ដុំមុខវិជ្ជាសិក្សា និងការជ្រើសរើសសិស្សចូលរៀនថ្នាក់បណ្ដុំមុខវិជ្ជាសិក្សា
- ចេញសេចក្ដីណែនាំដល់គ្រប់មន្ទីរអប់រំ យុវជន និងកីឡា ទាំងអស់ឱ្យជួយពិនិត្យ តាមដានលើការអនុវត្តលិខិតបទដ្ឋានគតិយុត្តិដល់កម្រិតសាលារៀនជាប្រចាំ
- ណែនាំដល់សាលារៀនកម្រិតទុតិយភូមិទាំងអស់ ឱ្យអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិ ប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវខ្ពស់
- ផ្ដល់សិទ្ធ និងគាំទ្រដល់សាលារៀនក្នុងការរៀបចំ និងបង្កើតយន្តការការប្រឡងដើម្បីជ្រើសរើសសិស្សចូលរៀនថ្នាក់បណ្ដុំមុខវិជ្ជាសិក្សានីមួយៗ។

**មន្ទីរអប់រំ យុវជន និងកីឡា**

- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិ និងសេចក្ដីណែនាំផ្សេងៗ ដល់ការិយាល័យអប់រំ យុវជន និងកីឡា និងសាលារៀនកម្រិតទុតិយភូមិ ក្រោមឱវាទរបស់ខ្លួនទាំងអស់
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ លើការអនុវត្តរបស់សាលារៀនជាប់ជាប្រចាំ និងប្រកបដោយទំនួលខុសត្រូវ។

**សម្រាប់សាលារៀន**

- អនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា ប្រកបដោយទំនួលខុសត្រូវខ្ពស់
- ចាត់តាំង និងប្រគល់ភារកិច្ចដល់គ្រូបង្រៀនកម្រិតឧត្ដមត្រូវតាមមុខវិជ្ជាឯកទេសឱ្យអស់ពីលទ្ធភាព សម្រាប់ការបង្រៀនថ្នាក់បណ្ដុំមុខវិជ្ជាសិក្សានីមួយៗ
- រៀបចំការប្រឡងជ្រើសរើសសិស្សឱ្យចូលរៀនថ្នាក់បណ្ដុំមុខវិជ្ជាសិក្សានីមួយៗ ប្រកបដោយភាពយុត្តិធម៌ និងតម្លាភាព
- បង្កើតគណៈកម្មការប្រឹក្សាពិគ្រោះ និងផ្ដល់យោបល់ ដើម្បីជួយសិស្សដែលមានបញ្ហាក្នុងការជ្រើសរើសបណ្ដុំមុខវិជ្ជាសិក្សា ឬក្នុងការសិក្សារៀនសូត្រ។

**សម្រាប់គ្រូបង្រៀន**

- ជាអ្នកផ្ដល់ប្រឹក្សា និងការលើកទឹកចិត្តដល់សិស្សានុសិស្សក្នុងការជ្រើសរើសថ្នាក់បណ្ដុំមុខវិជ្ជាសិក្សានីមួយៗ
- ខិតខំស្រាវជ្រាវមេរៀន និងបង្រៀនតាមមុខវិជ្ជាឯកទេសរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ និងតាមគរុកោសល្យ
- បន្តការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹង និងជំនាញថ្មីៗ សម្រាប់អភិវឌ្ឍការបង្រៀនឱ្យកាន់តែទាក់ទាញ និងប្រកបដោយគុណភាព
- ត្រូវបន្តជួយសិស្សរៀនយឺត ក្នុងថ្នាក់បណ្ដុំមុខវិជ្ជាសិក្សានីមួយៗ ដើម្បីឱ្យពួកគេទទួលបានចំណេះដឹង និងមានសមត្ថភាពពិតប្រាកដ។

## សម្រាប់សិស្ស

- ត្រូវខិតខំរៀនសូត្រគ្រប់មុខវិជ្ជាទាំងអស់ ដែលមាននៅក្នុងកម្មវិធីសិក្សាគោលដែលក្រសួងអប់រំ យុវជន និងកីឡា បានកំណត់
- ត្រូវជ្រើសរើសថ្នាក់បណ្តុំមុខវិជ្ជាសិក្សាណាដែលត្រូវទៅតាមចំណូលចិត្ត និងសមត្ថភាពរបស់ខ្លួន
- ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើស ដើម្បីអាចចូលរៀនថ្នាក់បណ្តុំមុខវិជ្ជាសិក្សាណាមួយក្នុងចំណោមថ្នាក់បណ្តុំមុខវិជ្ជាសិក្សាទាំងពីរ។

សរុបសេចក្តីមក ដើម្បីឱ្យការអប់រំមានគុណភាពល្អពិតប្រាកដ លុះត្រាតែសិស្សានុសិស្សទទួលបានការអប់រំប្រកបដោយគុណភាព និងមានជំនាញច្បាស់លាស់។ ប៉ុន្តែដើម្បីឱ្យសិស្សានុសិស្សទទួលបានការអប់រំ និងជំនាញទាំងនេះ លុះត្រាតែសិស្សានុសិស្សបានរៀនមុខវិជ្ជាដែលត្រូវទៅនឹងចំណូលចិត្ត និងសមស្របតាមសមត្ថភាពរបស់ពួកគេ។ ហើយដើម្បីឱ្យសិស្សានុសិស្សអាចចូលរៀនក្នុងថ្នាក់បណ្តុំមុខវិជ្ជាដែលសមស្របតាមសមត្ថភាព លុះត្រាតែមានការប្រឡងជ្រើសរើសឱ្យចូលរៀនថ្នាក់បណ្តុំមុខវិជ្ជាសិក្សា។ ដូចនេះហើយក្រសួងអប់រំ យុវជន និងកីឡា គួរបង្កើតលិខិតបទដ្ឋានគតិយុត្តិ ដើម្បីអនុញ្ញាតឱ្យមានការប្រឡងជ្រើសរើសសិស្សចូលរៀនថ្នាក់បណ្តុំមុខវិជ្ជាសិក្សា ប្រសិនបើចង់ទទួលបានធនធានមនុស្សដែលប្រកបដោយសមត្ថភាពពិតប្រាកដ។

## ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា ២០៣០. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០០៦). កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋាន ចំណេះទូទៅ. ភ្នំពេញ: នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០០៩). គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធី សិក្សាចំណេះទូទៅ. ភ្នំពេញ: នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ.

Rajani Shrestha, Jennifer Shin, Karen Tietjen. (២០១១). ការវិភាគនិន្នាការសិស្ស បោះបង់ការសិក្សានៅកម្ពុជា-ការទប់សិស្សបោះបង់ការសិក្សា. ភ្នំពេញ ប្រទេសកម្ពុជា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៥). ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និង បច្ចេកទេស. ភ្នំពេញ.

រដ្ឋសភា. (២០០៧). ច្បាប់ស្តីពីការអប់រំ: ព្រះរាជក្រម ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧. ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). ផែនទីបង្ហាញផ្លូវ ការអប់រំនៅកម្ពុជា ឆ្នាំ ២០៣០. ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨ ២០២៣. ភ្នំពេញ.

រាជរដ្ឋាភិបាលកម្ពុជា. (២០១៨). យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤. ភ្នំពេញ.

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា. (២០០៨). រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា . ភ្នំពេញ.

វិជ្ជានន្ទ, ខ. (២០០៥). របាយការណ៍សាកលលោកស្ដីពីការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ ២០០៥. ភ្នំពេញ. រោងពុម្ព ឥន្ទ្រីមាស.

ភាពជាដៃគូអប់រំអង្គការក្រៅរដ្ឋាភិបាល. (២០១៥). វិស័យអប់រំឆ្នាំ២០៣០: សេចក្ដីប្រកាសទីក្រុងអ៊ីនឈុន ឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា. ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧). សន្និបាតបូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១៥-២០១៦ និងទិសដៅឆ្នាំសិក្សា២០១៦-២០១៧. ភ្នំពេញ.

David Finegold and Alexis Spencer Notabartolo. 21st Century Competencies and Their Impact: An Interdisciplinary Literature Review.

Warren G. Findley and Mariam M. Bryan. (1971). Ability Grouping: 1970- Status, Impact, and Alternatives. Athens.

Nicold Baker. (2018). Grouping Students by Ability: Is There a Different in Academic Achievement?

Maureen T. Hallinan. (1987). The Social Organization of Schools: Ability Grouping and Student Learning. New York.

Anna Kathryn McCarter. (2014). Ability Grouping in Elementary Education. East Tennessee.

Michael Kintz. (2011). Ability Grouping and How It Is Affecting American Classrooms. DigitalCommon@.C.O.D.

Susan Hallam, Judith Ireson, Veronica Lister, Indrani Andon Chaudhury. Ability Grouping Practices in Primary School: A Survey. London.

Braddock, Jomills Henry,II; Slavin, Robert E. (1992). Why ability grouping must end: Achieving Excellence and Equity in American Education. Baltimore.

Francis, B. Archer, L. Hodgen, J. Pepper, D. Taylor, B. & Travers, M. Exploring the relative lack of impact of research on 'ability grouping' in England: a discourse analytic account. London.

Hallam, S. & Deathe, K. (). Ability grouping: Year group differences in self-concept and attitudes of secondary school pupils. (London, London of University).

Mansor, A. N.,Maniam, P. P., Hunt, M. C., & Nor, M. Y.M. (2016). Benefits and Disadvantages of Streaming Practices to Accommodate Students by Ability. Kuala Lumpur. Retrieved from http://dx.doi.org/10.4236/ce.2016.717241.

Cohen, L. Manion, L. & Morrison, K. (2004). Advantages of mixed-ability groups

Muneerah S. Al-Subaiei. (2017). Challenges in Mixed Ability Classes and Strategies Utilized by ELI Teachers to Cope with Them. Kingdom of Saudi Arabia. Canadian Center of Science and Education.

Aftab, J. (2015). Teachers' Beliefs about Differentiated Instructions in Mixed Ability Classrooms: A Case of Time Limitation. Vol. 2 No. p (94 – 114).

Crosby, M. S. & Owens, E. M. (1993). The Disadvantage s of Tracking and Ability Grouping: A Look at Cooperative Learning as an Alternative. South Carolina.

Reyes, P. M & Rodríguez, J. F. (2005). Teaching English in Mixed-ability Classrooms

Brulles, D. Kerren, L. & Brown, M. (2018). Flexible Grouping and Cooperative Learning. Minneapolis. Free Spirit Publishing Inc.

Ford, O. (2017). Streaming of Classes, Social Comparison, and Students′ Self-Concept. Canterbury.

Robert C. Spear. (1994). Teacher Perceptions of Ability Grouping Practices in Middle Level Schools. Massachusetts.

Mirani, S & Chunawala, S. (2008).TEACHERS′ PERCEPTIONS OF DEALING WITH MIXED ABILITY CLASSROOMS. Bombay.

Chisaka, B.C. Vakalisa, N.C.G. (2003). Some effects of ability grouping in Harare secondary schools: a case study. Zimbabwe

Chris M. M. Smith and Margaret J. Sutherland. (2003). Setting or mixed ability? Teachers′ views of the organisation of pupils for learning. Glasgow.

## ឧបសម្ព័ន្ធទី១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ [illegible] អយក.វិជអ

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩

**ជម្រាបមក**

**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**

**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**

**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ** ៖ ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង** ៖ កម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៥១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**

- -ខុទ្ទកាល័យឯកឧត្ដមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- -សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- -អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- -កាលប្បវត្តិ
- -ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :** ១១៩ **ទជអ. ភក**

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ វ៉ាឡង់ទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអើល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណាវី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត វ៉ារុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ឆាយ បូនិ | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា គត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណារ៉ា | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញៀត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៉ុម សូគា | ប | ខេត្តកណ្ដាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្ដាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |

1

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៤៨៤ គេហទំព័រ៖ www.nie.edu.kh

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វៀរិ | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ គុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គឹមសាន | ប | ខេត្តកណ្ដាល |
| ២៥ | វ៉ា សុភក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាស្មី | ប | ខេត្តកណ្ដាល |
| ២៧ | ស៊ើយ វេស្ស៊ី | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គឹមឈៀន | ប | ខេត្តកណ្ដាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហៃល ម៉ូណា | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វិរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ុន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ុំ សុធិ | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ឹម សិរីវុធ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធិ | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គឹមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

**កន្លែងទទួល៖**

- សាលារាជធានី-ខេត្តពាក់ព័ន្ធ
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
- មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

បណ្ឌិត.សៀង សុវណ្ណរ៉ា

2

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (០៨៥-២៣) ២១៥/៥៥៤ គេហទំព័រៈ www.nie.edu.kh

# ឧបសម្ព័ន្ធទី២៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកំពង់ចាម**
**មន្ទីរអប់រំ យុវជន និងកីឡា**
លេខៈ ...៧៧៥/១៩... ឧទន.រប

## លិខិតឧទ្ទេសនាម

**យោង ៖** លិខិតលេខ១៨៨៥.អយក.វជអ.ចុះថ្ងៃព្រហស្បតិ៍ ១៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦។

និស្សិតថ្នាក់បិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ដែលនឹងប្រព្រឹត្តទៅចាប់ពី ថ្ងៃទី១០ ខែមិថុនា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ នៅ ក្រុងកំពង់ចាម- ស្រុកជើងព្រៃ- ស្រុកចំការលើ- ស្រុកកងមាស- ស្រុកបាធាយ និងស្រុកព្រៃឈរ ៖

| | | |
|---|---|---|
| ១ - លោក | **សាម សុនិត** | និស្សិត |
| ២ - លោក | **លុន ហ៊ាប** | និស្សិត |
| ៣ - លោក | **លី កុសល** | និស្សិត |
| ៤ - លោក | **អៀង គឹមឈាន** | និស្សិត |
| ៥ - លោក | **ឡុង ចំណាន** | និស្សិត |
| ៦ - លោក | **ទុយ សុវណ្ណារិទ្ធ** | និស្សិត |

ថ្ងៃអង្គារ...១០.រោច. ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
កំពង់ចាម ថ្ងៃទី..២៨... ខែឧសភា ឆ្នាំ២០១៩
**ជ. ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**
**អនុប្រធាន**

**ជួង_សុផាត**

**កន្លែងទទួល ៖**
*-ការិ.អ.យ.ក ក្រុង/ស្រុក កំពង់ចាម,ជើងព្រៃ,ចំការលើ កងមាស,បាធាយ និងព្រៃឈរ*
*"ដើម្បីជូនជ្រាបជាព័ត៌មាន"*
*-គ្រឹះស្ថានសិក្សាពាក់ព័ន្ធ*
*«ដើម្បីសហការ»*
*-សាមីខ្លួន "ដើម្បីអនុវត្ត "*
*- កាលប្បវត្តិឯកសារ ៖ ការិ.រដ្ឋបាល*

លិខិតឧទ្ទេសនាម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡា
ខេត្តកំពង់ចាម
ការិយាល័យរដ្ឋបាល

## កំណត់បង្ហាញលិខិតចូល

អង្គភាពផ្ញើ៖ [illegible] លេខ 1885 [illegible]
ចុះថ្ងៃទី 18 ខែ 05 ឆ្នាំ ២០19។

ខ្លឹមសារ ៖ [illegible]

| ប្រធាន ឬអនុប្រធានការិយាល័យរដ្ឋបាល | មន្ត្រីរៀប និងឯកសារ |
| --- | --- |
| គោរពជូនលោកប្រធានមន្ទីរពិនិត្យ និងចាត់ចែងឱ្យការិយាល័យជំនាញក្រោមឱវាទ "ដើម្បីអនុវត្ត" | ជូនលោកប្រធាន ឬអនុប្រធានការិយាល័យរដ្ឋបាល ដើម្បីពិនិត្យ និងផ្តល់យោបល់ជូនលោកប្រធានមន្ទីរ |
| ថ្ងៃទី 28 ខែ 05 ឆ្នាំ ២០19 | ថ្ងៃទី 28 ខែ 05 ឆ្នាំ ២០19 |
| ហត្ថលេខា | ហត្ថលេខា |
| [illegible] | [illegible] |

ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម

[illegible]

ថ្ងៃទី 28 ខែ 05 ឆ្នាំ ២០19

ហត្ថលេខា

# ឧបសម្ព័ន្ធទី៣៖ កម្រងសំណួរ

## កម្រងសំណួរសម្រាប់គ្រូបង្រៀន និងនាយក

ខ្ញុំបាទឈ្មោះ ឡុង ចំណាន ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៦នៃវិទ្យាស្ថានជាតិអប់រំ កំពុងសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី ទស្សនៈរបស់គ្រូ និងនាយកសាលាក្នុងការតម្រង់ទិសសិស្សឱ្យជ្រើសរើសមុខវិជ្ជាសិក្សានៅមធ្យមសិក្សាទុតិយភូមិស្របតាមតម្រូវការរបស់ខ្លួន។ ការស្រាវជ្រាវនេះមានគោលបំណងឱ្យឃើញពីទស្សនៈរបស់នាយកសាលា និងគ្រូបង្រៀនកម្រិតទុតិយភូមិចំពោះការជួយសិស្សសម្រាប់ការជ្រើសរើសមុខវិជ្ជាត្រូវរៀននៅថ្នាក់ទុតិយភូមិ។ ដូច្នេះ សូមលោក លោកស្រី មេត្តាផ្តល់ព័ត៌មានពិតដល់ការស្រាវជ្រាវរបស់ខ្ញុំបាទដោយក្តីអនុគ្រោះផង។ ព័ត៌មានទាំងអស់នេះមានសារៈសំខាន់ណាស់សម្រាប់ការជួយតម្រង់ទិសដល់សិស្សានុសិស្សនៅពេលពួកគេរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

ខ្ញុំបាទសូមធានានឹងរក្សាការសម្ងាត់ចំពោះព័ត៌មានដែលបានផ្តល់ឱ្យ ហើយព័ត៌មានទាំងអស់នេះត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងនៃការស្រាវជ្រាវតែប៉ុណ្ណោះ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបំពេញកម្រងសំណួរនេះ។

សូមបំពេញព័ត៌មានខាងក្រោម៖

១. ភេទ៖ ☐ប្រុស ☐ស្រី តួនាទី៖.......................... ឈ្មោះអង្គភាព៖ វិ..............................................

២. ឯកទេសដើម៖ ..........................................

៣. អាយុ (ឆ្នាំ)៖ .........

៤. ចំណង់ចំណូលចិត្តនៃការរៀនរបស់សិស្ស ☐វិទ្យាសាស្ត្រសង្គម ☐វិទ្យាសាស្ត្រពិត

**១.មូលហេតុដែលសិស្សានុសិស្សជ្រើសរើសបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត៖**

(សូមគូសសញ្ញា ☑ តែមួយប៉ុណ្ណោះនៅក្នុងប្រអប់)

៥. សិស្សចូលរៀនថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត តាមចំណូលចិត្តរបស់ខ្លួន

☐ យល់ស្រប ☐ អព្យាក្រឹត ☐ មិនយល់ស្រប

៦. សិស្សចូលរៀនថ្នាក់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត តាមការណែនាំរបស់គ្រួសារ

☐ យល់ស្រប ☐ អព្យាក្រឹត ☐ មិនយល់ស្រប

៧. សិស្សចូលរៀនថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត តាមការរៀចំរបស់សាលារៀន

☐ យល់ស្រប ☐ អព្យាក្រឹត ☐ មិនយល់ស្រប

៨. សិស្សចូលរៀនថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត តាមតម្រូវការទីផ្សារការងារ

☐ យល់ស្រប ☐ អព្យាក្រឹត ☐ មិនយល់ស្រប

៩. សិស្សចូលរៀនថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត តាមលំដាប់ពិន្ទុមុខវិជ្ជា

☐ យល់ស្រប ☐ អព្យាក្រឹត ☐ មិនយល់ស្រប

១០. សិស្សចូលរៀនថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត តាមលំដាប់ពិន្ទុនៃការប្រឡង

☐ យល់ស្រប ☐ អព្យាក្រឹត ☐ មិនយល់ស្រប

១១. សិស្សចូលរៀនថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត តាមការផ្ដល់ប្រឹក្សាពីអ្នកជំនាញ

☐ យល់ស្រប ☐ អព្យាក្រឹត ☐ មិនយល់ស្រប

**២.ការបែងចែកថ្នាក់រៀន៖**

១២. តើការបែងចែកថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រពិតនៅសាលារៀនរបស់ លោក លោកស្រី ចាប់ពីកម្រិតថ្នាក់ទីប៉ុន្មាន?

☐ ថ្នាក់ទី១០ ☐ ថ្នាក់ទី១១ ☐ ថ្នាក់ទី១២ ☐ ថ្នាក់មធ្យមសិក្សាបឋមភូមិ

១៣. តើការបែងចែកថ្នាក់បណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រពិត គួរចាប់ពីកម្រិតថ្នាក់ទីប៉ុន្មាន?

☐ ថ្នាក់ទី១០ ☐ ថ្នាក់ទី១១ ☐ ថ្នាក់ទី១២ ☐ ថ្នាក់មធ្យមសិក្សាបឋមភូមិ

១៤. បែងចែកថ្នាក់រៀន ទៅតាមការស្ម័គ្រចិត្តរបស់សិស្ស ដោយមិនគិតពីសមត្ថភាពរបស់ពួកគាត់

☐ ល្អ ☐ ល្អបង្គួរ ☐ ល្អមធ្យម ☐ មិនល្អ

១៥. បែងចែកថ្នាក់រៀន ទៅតាមមុខវិជ្ជា (ឧទាហរណ៍៖ ថ្នាក់គណិតវិទ្យា ថ្នាក់ភាសាខ្មែរ...)

☐ ល្អ ☐ ល្អបង្គួរ ☐ ល្អមធ្យម ☐ មិនល្អ

១៦. បែងចែកថ្នាក់រៀន ទៅតាមសមត្ថភាពរបស់សិស្ស (ឧទាហរណ៍៖ ថ្នាក់សិស្សពូកែ ថ្នាក់សិស្សមធ្យម...)

☐ ល្អ ☐ ល្អបង្គួរ ☐ ល្អមធ្យម ☐ មិនល្អ

**៣.ទស្សនៈរបស់អ្នកដើម្បីតម្រង់ទិសសិស្សជ្រើសរើសថ្នាក់បណ្ដុំមុខវិជ្ជាឱ្យបានត្រឹមត្រូវ៖**

(សូមគូសសញ្ញា ☑ ចម្លើយអាចលើសពីពីរ)

១៧. តើគ្រូបង្រៀនអាចជួយសិស្សជ្រើសរើសថ្នាក់បណ្ដុះមុខវិជ្ជាសិក្សាបានត្រឹមត្រូវតាមរបៀបណាខ្លះ?

- ☐ ផ្ដល់ប្រឹក្សាដល់សិស្សម្នាក់ៗ
- ☐ ផ្ដល់ការណែនាំជារួមជាមួយសិស្សច្រើននាក់
- ☐ ផ្ដល់ការណែនាំពេលគោរពទង់ជាតិ
- ☐ បញ្ជ្រាបព័ត៌មានពេលកំពុងបង្រៀន
- ☐ បង្កើតជាក្រុមប្រឹក្សា ដើម្បីជួយដល់សិស្ស
- ☐ ពន្យល់ណែនាំអាណាព្យាបាល ឱ្យយល់ស្របតាមការសម្រេចចិត្តរបស់កូនៗ
- ☐ ប្រឡងជ្រើសរើសទូទៅ មុនពេលចូលរៀន
- ☐ ប្រឡងវាស់សមត្ថភាព លើមុខវិជ្ជា គណិតវិទ្យា និងភាសាខ្មែរ
- ☐ ប្រឡងជ្រើសរើសសម្រាប់តែ ថ្នាក់បណ្ដុះមុខវិជ្ជាវិទ្យាសាស្ត្រពិត

១៨. តើលោក លោកស្រីយល់ថាការជ្រើសរើសសិស្សចូលរៀន ថ្នាក់បណ្ដុះមុខវិជ្ជាសព្វថ្ងៃល្អឬទេ? ព្រោះអ្វី? បើមិនល្អ ព្រោះអ្វី?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៩. តើលោក លោកស្រីយល់យ៉ាងណា ដើម្បីឱ្យការជ្រើសរើសសិស្សចូលរៀន ថ្នាក់បណ្ដុះមុខវិជ្ជាសិក្សាកាន់តែល្អប្រសើ? ព្រោះអ្វី?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................